00268521

ការពារៈ(1) ៩៧/8

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
## ចំពោះមុខសហចៅក្រមស៊ើបអង្កេត

| | |
|---|---|
| សំណុំរឿងលេខ: | ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស |
| កាលបរិច្ឆេទដាក់ឯកសារ: | ៣១ ធ្នូ ២០០៨ |
| ភាគីបញ្ជូន | ការិយាល័យសហព្រះរាជអាជ្ញា |
| ភាសាដើម: | អង់គ្លេស |
| ប្រភេទឯកសារ: | សាធារណៈ |

---

# សេចក្តីអង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញា
# ស្តីពី
# សហគមន៍ក្រុងកម្ពុជា

---

**បញ្ជូនដោយ៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជាលាង

លោក Robert PETIT

លោក យ៉េត ចរិយា

លោក William SMITH

លោក តាន់ សេណារ៉ុង

លោក Anees AHMED

**បញ្ជូនទៅ៖**

**សហចៅក្រមស៊ើបអង្កេត៖**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Marcel LEMONDE

**សហមេធាវីរបស់លោក អៀង សារី៖**

លោក អាង ឧត្តម

លោក Michael KARNAVAS

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 31 / 12 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

**ឯកសារដើម**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 31 / 12 / 2008
ម៉ោង (Time/Heure): 9:55
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

## ១. សេចក្តីផ្តើម

១. សេចក្តីអង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញានេះ (“សេចក្តីអង្កេតបន្ថែម”) រៀបរាប់លម្អិតអំពីការយកទម្រង់នៃការទទួលខុសត្រូវមកអនុវត្តនៅអ.វ.ត.ក ដែលគេហៅថា សហកម្មឧក្រិដ្ឋកម្មរួម។ ជាពិសេស សេចក្តីអង្កេតបន្ថែមនេះនឹងរៀបរាប់លម្អិត អំពីមូលហេតុនៃការអនុវត្តការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទូលាយ “សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទីIII” នៅចំពោះមុខតុលាការនេះ។ សេចក្តីអង្កេតបន្ថែមនេះ ក៏ឆ្លើយតបនឹងការលើកឡើងនូវទឡ្ហីករណ៍មិនត្រឹមត្រូវចំពោះបញ្ហានេះ នៅក្នុងពាក្យសុំរបស់ជនត្រូវចោទ អៀង សារី (“ពាក្យសុំ”)[1] និងសេចក្តីអង្កេតបន្ថែមរបស់ជនត្រូវចោទ អៀង សារី (“សេចក្តីអង្កេតបន្ថែម”)[2]។

២. ពាក្យសុំ បានលើកឡើងនូវអំណះអំណាងចំបងចំនួនបី ដែលអំណះអំណាងភាគច្រើនលើកឡើងវិញនៅក្នុងសេចក្តីអង្កេតបន្ថែម ដើម្បីជួយគាំទ្រទឡ្ហីករណ៍ថា សហកម្មឧក្រិដ្ឋកម្មរួមមិនអាចយកមកអនុវត្តនៅអ.វ.ត.កបានទេ។ ទីមួយ ពាក្យសុំនេះបានលើកអំណះអំណាងថា សហកម្មឧក្រិដ្ឋកម្មរួម ដែលត្រូវបានអង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី(តុលាការ ICTY) យកមកអនុវត្តនៅក្នុងសេចក្តីសម្រេច *Tadic* គឺជាច្បាប់តុលាការប្រឌិតឡើង ដែលមិនមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬទាន់មិនមាននៅក្នុងឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៩ នៅឡើយទេ។ ទីពីរ ពាក្យសុំបានលើកឡើងថា សហកម្មឧក្រិដ្ឋកម្មរួមមិនអាចយកមកអនុវត្តចំពោះមុខ អ.វ.ត.ក ទេ ពីព្រោះសហកម្មឧក្រិដ្ឋកម្មរួមមិនមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ហើយច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនអាចយកមកអនុវត្តនៅក្នុងតុលាការកម្ពុជាទេ។ ទីបី ពាក្យសុំ បាន

---

[1] *រឿងក្តីរបស់លោកអៀង សារី* ពាក្យសុំរបស់លោក **អៀង សារី** ប្រឆាំងនឹងការអនុវត្តទម្រង់ទទួលខុសត្រូវ ដែលហៅថាសហកម្មឧក្រិដ្ឋកម្មរួមនៅអ.វ.ត.ក សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០០៨ ERN 00208225-00208240, D97 [ហៅកាត់ថា ពាក្យសុំ]។

[2] *រឿងក្តីរបស់លោកអៀង សារី* សេចក្តីអង្កេតបន្ថែមរបស់លោក **អៀង សារី** ស្តីពីការអនុវត្តទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួមនៅអ.វ.ត.ក រឿងក្តីលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ERN 00244390-00244418, D97 [ហៅកាត់ថា សេចក្តីអង្កេតបន្ថែម]។

លើកឡើងថា ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួមមានលក្ខណៈទូលំទូលាយ ដូច្នេះការអនុវត្តទ្រឹស្តីនេះចំពោះមុខ អ.វ.ត.ក នឹងធ្វើឱ្យ "ការទទួលខុសត្រូវនឹងធ្លាក់ទៅលើសមាជិកពាក់ព័ន្ធថ្នាក់ខ្ពស់នៅក្នុងសង្គមកម្ពុជា" ហេតុដូច្នេះធ្វើឱ្យខូចកេរ្តិ៍ឈ្មោះរបស់ពួកគេ[3]។

៣. សេចក្តីអង្កេតបន្ថែមនេះ នឹងលើកទឡ្ហីករណ៍ប្រឆាំងនឹងអំណះអំណាងទាំងបីខាងលើនេះ ដើម្បីបង្ហាញថា ទម្រង់ទាំងបីរបស់សហកម្មឧក្រិដ្ឋកម្មរួម អាចយកមកអនុវត្ត ដោយសារមូលហេតុដូចខាងក្រោម៖

ក. ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម មាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិចាប់តាំងពីចុងទសវត្សរ៍ឆ្នាំ១៩៤០ នៅពេលទ្រឹស្តីនេះបង្កើតឡើងដោយច្បាប់ និងយុត្តិសាស្ត្ររបស់តុលាការ Nuremberg និងតុលាការឧក្រិដ្ឋកម្មសង្គ្រាមជាបន្តបន្ទាប់ ចាប់តាំងពីក្រោយសង្គ្រាមលោកលើកទីពីរ។ ថាតើប្រភពក្រោយឆ្នាំ១៩៧៥ ត្រូវបានដកស្រង់គាំទ្រទឡ្ហីករណ៍សហព្រះរាជអាជ្ញាយ៉ាងណានោះ គឺសុទ្ធតែជាប្រភពដែលទទួលស្គាល់ និងគាំទ្រអង្គហេតុនេះ និងបញ្ជាក់ច្បាស់ឱ្យស្របតាមទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម។

ខ. ទម្រង់ទាំងបីរបស់សហកម្មឧក្រិដ្ឋកម្មរួម អាចយកមកអនុវត្តនៅក្នុងតុលាការនេះ ពីព្រោះមាត្រា២៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានផ្តល់ការអនុញ្ញាតចំពោះការអនុវត្តបែបនេះ ពីព្រោះច្បាប់ទំនៀមទម្លាប់អន្តរជាតិអាចយកមកអនុវត្ត "នៅក្នុងតុលាការខ្នាតអន្តរជាតិ ដែលប្រើប្រាស់វិធាននិងបទដ្ឋានអន្តរជាតិ"[4] (ដូចគ្នានឹងតុលាការកម្ពុជាដែរ) និងដោយសារសហកម្មឧក្រិដ្ឋកម្មរួម គឺជាទម្រង់ទទួលខុសត្រូវដែលអាចប្រមើលមើលទុកជាមុន នៅពេលប្រព្រឹត្តបទល្មើស ដែលស្ថិតក្នុងយុត្តាធិការរបស់តុលាការនេះ (ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩)។

---

[3] ពាក្យសុំ ទំព័រទី១។

[4] *រឿងក្តីរបស់លោក នួន ជា* សេចក្តីសម្រេចជាសាធារណៈ: ស្តីពីបណ្តឹងឧទ្ធរណ៍ជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ **នួន ជា** ចំពោះលោកចៅក្រម **ន័យ ថុល** សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០១), ERN 00160734-00160742, C11/29 ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ កថាខណ្ឌទី៣០ [ហៅកាត់ថា សេចក្តីសម្រេចបណ្តឹងជំទាស់ចំពោះលោកចៅក្រម **ន័យ ថុល**]។

គ. ផ្ទុយនឹងអំណះអំណាងរបស់ជនត្រូវចោទ ប្រសិនបើទម្រង់ទាំងបីរបស់សហកម្មឧក្រិដ្ឋកម្មរួម ត្រូវបានយកមកអនុវត្តត្រឹមត្រូវ វាប្រាកដជានាំឱ្យមានការកំណត់នូវវិសាលភាពនៃការទទួលខុសត្រូវច្បាស់លាស់។ ដូច្នេះ ទម្រង់នៃការទទួលខុសត្រូវនឹងមិនដាក់ពិរុទ្ធដោយសារ "ការពាក់ព័ន្ធ" ឬ "រាលដាលឱ្យខូចកេរ្តិ៍ឈ្មោះ" ដោយសារតែការទទួលខុសត្រូវ ផ្នែកព្រហ្មទណ្ឌ ដល់បុគ្គល ដែលបានលើកឡើងនៅក្នុងពាក្យសុំនោះទេ។

៤. រឿងក្ដីជាច្រើនចំពោះមុខតុលាការ ICTY[5] តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា ("តុលាការ ICTR")[6] តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ("តុលាការ SCSL")[7]

---

[5] *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Tadic* សេចក្ដីសម្រេចសេចក្ដីសម្រេច អង្គជំនុំជម្រះតុលាការកំពូល សំណុំរឿងលេខ IT-94-1-A ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ [ហៅកាត់ថាសេចក្ដីសម្រេចអង្គជំនុំជម្រះតុលាការកំពូលរឿងក្ដី Tadic]។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Milutinovic* សេចក្ដីសម្រេចលើពាក្យសុំរបស់ Dragoljub Ojdanic តវ៉ានឹងយុត្តាធិការការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួម អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICTY សំណុំរឿងលេខ IT-99-37-AR72 ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៣ [ហៅកាត់ថា សេចក្ដីសម្រេច Milutinovic]។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Krnojelac* សេចក្ដីសម្រេច អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICTY សំណុំរឿងលេខ IT-97-25-A ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៣ កថាខណ្ឌទី៩៦។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Simic* សេចក្ដីសម្រេច អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICTY សំណុំរឿងលេខ IT-95-9-T ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៣ កថាខណ្ឌទី១៥៩។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Kvocka* សំណុំរឿងលេខ IT-98-30/1-A សេចក្ដីសម្រេច ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ កថាខណ្ឌទី១០៥ ទី៣០៩។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Krnojelac* សំណុំរឿងលេខ IT-97-25-A សេចក្ដីសម្រេច ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៣ កថាខណ្ឌទី៩៦ ទី១០០។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Brdjanin* សំណុំរឿងលេខ IT-99-36-A សេចក្ដីសម្រេច ថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌទី៣៩៥។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Brdjanin* សំណុំរឿងលេខ IT-99-36-A សេចក្ដីសម្រេចលើបណ្ដឹងចាត់របៀប ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៤។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Stakic* សំណុំរឿងលេខ IT-97-24-A សេចក្ដីសម្រេច ថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌទី១០១ ដល់ទី១០៤។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Krjaisnik* សំណុំរឿងលេខ IT-00-39-T សេចក្ដីសម្រេច ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៦ កថាខណ្ឌទី១០៨២។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Milosevic* សំណុំរឿងលេខ IT-02-54-T សេចក្ដីសម្រេចលើពាក្យសុំឱ្យដោះលែង ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៤ កថាខណ្ឌទី២៩១។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Krstic* សេចក្ដីសម្រេច អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICTY សំណុំរឿងលេខ IT-98-33-A ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤ កថាខណ្ឌទី១៤៤។

[6] *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Ntakirutimana* សំណុំរឿងលេខ ICTR-96-10-A និងលេខ ICTR-96-17-A សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌទី៤៦១ ដល់ទី៤៨៤។ *រឿងក្ដីរដ្ឋ*

00268525

ឯកសារ: D97/8

និងក្រុមប្រឹក្សាពិសេសសម្រាប់ជំនុំជម្រះបទល្មើសធ្ងន់ធ្ងរនៅប្រទេសទីម័រខាងកើត[8] បានទទួលស្គាល់ និងអនុវត្តទម្រង់ទាំងបីនៃការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួម។ ទម្រង់ទាំងបីនេះ មាន*ធាតុផ្សំសត្យានុម័តនៃបទឧក្រិដ្ឋ* ដូចខាងក្រោម៖ (១)បុគ្គលច្រើននាក់ (២) អត្ថិភាពផែនការរួម គម្រោងរួម ឬគោលបំណងរួម ដែលមាន ឬពាក់ព័ន្ធការប្រព្រឹត្តិបទល្មើសដែលមានចែងនៅក្នុងច្បាប់ពាក់ព័ន្ធ និង (៣) ការចូលរួមប្រព្រឹត្ត"ដ៏សំខាន់"របស់ជនជាប់ចោទនៅក្នុងផែនការរួម ដែលពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើសមួយក្នុងចំណោមបទល្មើសនានាដែលមានចែងនៅក្នុងច្បាប់ពាក់ព័ន្ធ[9]។ ប៉ុន្តែ ទម្រង់ទាំងបីរបស់សហកម្មឧក្រិដ្ឋកម្មរួម

---

*អាជ្ញា តទល់នឹង Rwamakuba* សំណុំរឿងលេខ ICTR-98-44-AR72.4 សេចក្តីសម្រេចលើបណ្តឹងចាត់របៀបទាក់ទងនឹងការអនុវត្តសហកម្មឧក្រិដ្ឋកម្មរួមចំពោះបទល្មើសប្រល័យពូជសាសន៍ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៤ កថាខណ្ឌទី១៤ រហូតដល់ទី៣០។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindanda* សំណុំរឿងលេខ ICTR-95-1-A សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌទី១៩៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Nchamihigo* សំណុំរឿងលេខ ICTR-20010630R50 សេចក្តីសម្រេចលើពាក្យសុំរបស់មេធាវីការពារក្តីស្តីពីកំហុសនៃការបង្កើតដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៦ កថាខណ្ឌទី១៤ និងទី២១។

[7] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Brima, Kamara និង Kanue (រឿងក្តី AFRC)* សំណុំរឿងលេខ SCSL-04-16-T សេចក្តីសម្រេចលើពាក្យសុំឱ្យដោះលែង អនុលោមតាមវិធាន៩៨ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌទី៣០៨ រហូតដល់៣២៦។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Norman, Fofana និង Kondewa (រឿងក្តី CDF)* សំណុំរឿងលេខ 04-14-T សេចក្តីសម្រេចលើពាក្យសុំឱ្យដោះលែង អនុលោមតាមវិធាន៩៨ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៥ កថាខណ្ឌទី១៣០។

[8] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Jose Cardoso Fereira* លេខ04/2001 ក្រុមប្រឹក្សាពិសេសសម្រាប់ជំនុំជម្រះបទល្មើសធ្ងន់ធ្ងរនៅក្នុងតុលាការថ្នាក់ស្រុករបស់Dili ប្រទេសទីម័រខាងកើត សេចក្តីសម្រេច ថ្ងៃទី៥ ខែមេសា ឆ្នាំ២០០៣ កថាខណ្ឌទី៣៦៧-៣៧៦ (បានរកឃើញជនជាប់ចោទមានពិរុទ្ធក្រោមទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម ដោយតុលាការបានអនុវត្តសេចក្តីសម្រេចរឿងក្តីTadic និងសេចក្តីសម្រេចរបស់តុលាការICTYផ្សេងទៀត ក្នុងការបកស្រាយបទបញ្ជាUNTAET ២០០០/១៥)។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង De Deus* លេខ2a/2004 ក្រុមប្រឹក្សាពិសេសសម្រាប់ជំនុំជម្រះបទល្មើសធ្ងន់ធ្ងរនៅក្នុងតុលាការថ្នាក់ស្រុករបស់Dili ប្រទេសទីម័រខាងកើត សេចក្តីសម្រេច ថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៥ នៅទំព័រទី១៣ (សម្រេចថា ទោះបីជាជនជាប់ចោទមិនវាយលើជនរងគ្រោះដោយផ្ទាល់ក្តី ប៉ុន្តែគាត់ត្រូវជាប់ពិរុទ្ធ "ដោយសារសហកម្មឧក្រិដ្ឋកម្មរួម" ពីព្រោះគាត់ជាផ្នែកនៃកម្លាំងដែលបានរៀបចំជាមុន ដោយមានចេតនាសម្លាប់ និងការប្រព្រឹត្តដោយប្រើប្រាស់កាំភ្លើង ពាលពាក្យគម្រាមកំហែង និងសម្លុតប្រជាជនគ្មានអាវុធ ហេតុដូចនេះវាជាការពង្រឹងការសម្រេចចិត្តរបស់ក្រុម។

[9] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Brdjanin* សំណុំរឿងលេខ IT-99-36-A សេចក្តីសម្រេចអង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌទី៤៣០។

ត្រូវតែមាន*ធាតុផ្សំអត្តនោម័តនៃចេតនាឧក្រិដ្ឋ* ខុសៗគ្នាដូចខាងក្រោម៖

ក. សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី I (ទម្រង់មូលដ្ឋាន) ដាក់ឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបុគ្គល នៅពេល "សហចុងចោទទាំងអស់ បានប្រព្រឹត្ត [...] ដោយអនុលោមតាមគម្រោងរួម [និង]មានចេតនាឧក្រិដ្ឋដូចគ្នា [...] ទោះបីជាសហចារីម្នាក់ៗបំពេញតួនាទីផ្សេងៗគ្នានៅក្នុង [សហកម្មឧក្រិដ្ឋកម្មរួមក៏ដោយ]"[10]។ *ធាតុផ្សំអត្តនោម័ត* ដែលតម្រូវឱ្យមាននៅក្នុងទម្រង់សហកម្មឧក្រិដ្ឋកម្មរួមនេះ គឺចេតនារួមគ្នារបស់សមាជិកទាំងអស់ក្នុងការប្រព្រឹត្តិបទល្មើសជាក់លាក់មួយ[11]។

ខ. សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទីII (ទម្រង់ជាប្រព័ន្ធ) "ត្រូវបានកំណត់ចរិតលក្ខណៈតាមរយៈអត្ថិភាពនៃការរៀបចំប្រព័ន្ធឧក្រិដ្ឋកម្មមួយ ជាពិសេសក្នុងករណីជំរុំប្រមូលផ្តុំ ឬជំរុំឃុំឃាំងខ្លួន"[12]។ *ធាតុផ្សំអត្តនោម័ត* ដែលតម្រូវឱ្យមាននៅក្នុងទម្រង់នេះ គឺការដឹងអំពីប្រព័ន្ធនៃការធ្វើបាបដោយផ្ទាល់ និងចេតនាបន្តប្រព្រឹត្តជាប្រព័ន្ធនៃការធ្វើបាបរួមនេះទៀត[13]។

គ. សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី III (ទម្រង់ទូលាយ) ដាក់ឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបុគ្គល នៅក្នុងករណីដែល"បុគ្គលណាមួយពាក់ព័ន្ធនឹងគោលបំណងរួមក្នុងការប្រព្រឹត្តិបទល្មើស ដែលចារីម្នាក់ក្នុងចំណោមនោះបានប្រព្រឹត្តបទល្មើស ដែលស្ថិតនៅខាងក្រៅផែនការរួម ប៉ុន្តែនឹងបង្កឱ្យមានផលវិបាកតាមធម្មតា និងអាចប្រមើលមើលទុកជាមុន ដែលអាចនឹងកើតឡើងដោយសារទង្វើដើម្បីសម្រេច

[10] សេចក្តីសម្រេចអង្គជំនុំជម្រះតុលាការកំពូលរឿងក្តីTadic កថាខណ្ឌទី១៩៦។

[11] *ដូចខាងលើដែរ* កថាខណ្ឌ២២៨។

[12] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kvocka* សំណុំរឿងលេខ IT-98-30/1-A សេចក្តីសម្រេចអង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ កថាខណ្ឌទី៨២។

[13] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តីTadic កថាខណ្ឌទី២២៨។

គោលបំណងរួមនោះ"[14]។ *ធាតុផ្សំអត្តនោម័ត* ក្នុងទម្រង់នេះ គឺចេតនាឧក្រិដ្ឋរួមរបស់ចារី ឬយ៉ាងហោចណាស់ ចុងចោទ "បានដឹងអំពីលទ្ធភាពដែលថា បទល្មើសផ្សេងណាមួយអាចនឹងកើតមាន ដោយសារផលវិបាកនៃការប្រតិបត្តិអំពើឧក្រិដ្ឋ ហើយ [ជននោះ] សុខចិត្តប្រថុយប្រថានទទួលយកផលវិបាកទាំងនោះ"[15]។

៥. សេចក្តីអង្កេតបន្ថែមនេះផ្តោតលើសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទីIII ទោះបីជាជនត្រូវចោទបានស្នើឱ្យសហចៅក្រមស៊ើបអង្កេតបដិសេធ ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួមគ្រប់ទម្រង់ទាំងអស់ក៏ដោយ ប៉ុន្តែមានតែសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី III ប៉ុណ្ណោះ ដែលទទួលការរិះគន់យ៉ាងខ្លាំង។ សហព្រះរាជអាជ្ញាឯកភាពនឹងសារណាចំនួនបីរបស់អ្នកដែលមិនមែន ជា ភាគីនៃរឿងក្តី ដែលអង្គបុរេជំនុំជម្រះស្នើសុំឱ្យដាក់នៅក្នុងបណ្តឹងឧទ្ធរណ៍លេខ ០០១/១៨-៧-២០០៧ (អ.ប.ជ ២) ក្នុងកម្រិតដែលសារណាទាំងបីនេះលើកឡើងអំពីការគាំទ្រនឹងសេចក្តីតអះអាងដែលថា សហកម្មឧក្រិដ្ឋកម្មទម្រង់ទីI និងទីII ស្ថិតនៅក្នុងផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិចាប់តាំងពីមុនឆ្នាំ១៩៧៥ និងអាចយកមកអនុវត្តនៅអ.វ.ត.ក[16]។

## ២. ជំនាស់បឋម

៦. ដូចបានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញា ចំពោះពាក្យសុំរបស់

---

[14] *ដូចខាងលើដែរ* កថាខណ្ឌទី២០៤។

[15] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តីTadic កថាខណ្ឌទី២២៨។

[16] ការដាក់សារណា១ចំនួនបីរបស់អ្នកមិនមែនជាភាគីនៃរឿងក្តី ដែលអនុញ្ញាតឱ្យដាក់ដោយអង្គបុរេជំនុំជម្រះនៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ឌុច។ សារណាទាំងនេះទទួលបានមកពី៖ (១) សាស្ត្រាចារ្យ Antonio Cassese របស់សាកលវិទ្យាល័យFlorence និងអ្នកផ្សេងៗទៀត (បានសន្និដ្ឋានថា ទម្រង់ទាំងបីរបស់សហកម្មឧក្រិដ្ឋកម្មរួម មាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិឆ្នាំ១៩៧៥), (២) សាស្ត្រាចារ្យចំនួនប្រាំបីពីវិទ្យាស្ថានGeorg-August Universitat Gottingen សម្រាប់ច្បាប់ព្រហ្មទណ្ឌ និងយុត្តិធម៌ (សន្និដ្ឋានថា សហកម្មឧក្រិដ្ឋកម្មទម្រង់ទី១ និងទម្រង់ទី២ មាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិឆ្នាំ១៩៧៥) និង (៣) សាស្ត្រាចារ្យចំនួនប្រាំពីមជ្ឈមណ្ឌលដើម្បីសិទ្ធិមនុស្ស និងពហុច្បាប់នៃសាកលវិទ្យាល័យMcGill (សន្និដ្ឋានថា សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី១ និងទី២ មាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិឆ្នាំ១៩៧៦)។

អៀង សារី ស្ដីពីសហកម្មឧក្រិដ្ឋកម្មរួម ("សេចក្ដីសន្និដ្ឋានតប")[17] ពាក្យសុំដាក់មិនបានត្រឹមត្រូវតាមវិធាន៥៣(១) នៃវិធានផ្ទៃក្នុង ("វិធានផ្ទៃក្នុង") ដែលមិនបានផ្ដល់សិទ្ធិជាក់ស្ដែងឬបង្កប់ណាមួយ ឱ្យជនត្រូវចោទ ដើម្បីស្នើសុំសហចៅក្រមស៊ើបអង្កេតចំពោះមូលហេតុណាមួយនោះទេ។ ពាក្យសុំបានស្នើសុំការកែប្រែមិនសមរម្យ ដោយសារវិធានផ្ទៃក្នុងមិនបានអនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេត ធ្វើការកែប្រែ ទាក់ទងនឹងបញ្ហាដែលមានក្នុងច្បាប់ជាធរមាន ឬទម្រង់នៃការទទួលខុសត្រូវណាមួយនោះទេ។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា ពាក្យសុំមិនអាចទទួលយកបាន ដោយផ្អែកលើមូលហេតុទាំងនេះ។

៧. បន្ថែមពីលើនេះ ពាក្យសុំ និងសេចក្ដីអង្កេតបន្ថែមត្រូវបានលើកឡើងយ៉ាងច្បាស់ដោយការពិចារណាលើច្បាប់ជាច្រើន ដែលមិនពាក់ព័ន្ធនឹងការធ្វើសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទេ។ នេះបង្ហាញយ៉ាងច្បាស់ពីការព្រួយបារម្ភផ្នែកនយោបាយ ដែលលើកឡើងទាក់ទងនឹងវិសាលភាពនៃការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួម ដែលអាចមាន នៅ អ.វ.ត.ក។ ទឡ្ហីករណ៍ដែលផ្អែកតាមសញ្ញាណនៃការបង្កើតទម្រង់សហកម្មឧក្រិដ្ឋកម្មរួមមិនត្រឹមត្រូវ និងធ្វើឱ្យអ្នកទាំងអស់មានការយល់ខុស ដូចដែលយើងនឹងឃើញច្បាស់នៅក្នុងការពិភាក្សាក្នុងផ្នែកទី៤ ខាងក្រោម។

## ៣. ទឡ្ហីករណ៍

៨. ជាបឋម គ្មានការលើកឡើងនូវវិវាទទាក់ទងនឹងទស្សនាទាន និងវិសាលភាពនៃគោលការណ៍ *គ្មានច្បាប់គឺគ្មានទោស (nullum crimen sine lege)*។ សេចក្ដីអង្កេតបន្ថែម មិនបានលើកឡើងទឡ្ហីករណ៍ពាក់ព័ន្ធមូលហេតុដែលតុលាការនេះគួរតែធ្វើការពិចារណា ថាតើច្បាប់ព្រះរាជាណាចក្រកម្ពុជាបានហាមឃាត់យ៉ាងតឹងរឹងលើប្រតិសកម្មនៃច្បាប់ ឬតើច្បាប់កម្ពុជាតម្រូវឱ្យមានលក្ខខណ្ឌអ្វីពិតប្រាកដនោះទេ។ ផ្ទុយទៅវិញ បញ្ហាដែលជាទឡ្ហីករណ៍ត្រង់ថា

---

[17] *រឿងក្ដីរបស់លោក អៀង សារី* សេចក្ដីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញាឆ្លើយតបពាក្យសុំរបស់លោក អៀង សារី ស្ដីពីសហកម្មឧក្រិដ្ឋកម្មរួម សំណុំរឿងលេខ ០០២/-១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៨ ERN 00211956-00211970, D97 កថាខណ្ឌទី៤ ដល់ទី៦ [ហៅកាត់ថា សេចក្ដីសន្និដ្ឋានតប]។

តើសហកម្មឧក្រិដ្ឋកម្មរួម (និងជាពិសេស ការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទូលាយ) ជាវិធានស្ថិតនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ១៩៧៥ ហើយឬនៅ និងថាតើសហកម្មឧក្រិដ្ឋកម្មរួមអាចយកមកអនុវត្តនៅអ.វ.ត.ក ឬមិនអាច។

## ក. ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួមគឺជាផ្នែកមួយក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិចាប់តាំងពីមានតុលាការនៅ Nuremberg

៩. ទម្រង់ទាំងបីរបស់សហកម្មឧក្រិដ្ឋកម្មរួមគឺជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចាប់តាំងពីមុនឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៩។ ការលើកឡើងនេះ បានស្តែងចេញតាមរយៈច្បាប់អន្តរជាតិ រឿងក្តី និងសេចក្តីប្រកាសអាជ្ញាព្រឹត្ត ព្រមទាំងរឿងក្តីក្នុងស្រុកនានា ដែលគាំទ្រអត្ថិភាពពីមុនរបស់សហកម្មឧក្រិដ្ឋកម្មរួម។ ទាំងអស់នេះ ផ្តល់នូវភស្តុតាងសមហេតុផលនៃការអនុវត្តយ៉ាងទូលំទូលាយរបស់រដ្ឋ និងគតិច្បាប់ដែលបង្កើតច្បាប់ទំនៀមទម្លាប់អន្តរជាតិ[18]។

១០. ការរួមបញ្ចូល"ផែនការរួម"នៃទម្រង់ទទួលខុសត្រូវក្នុងធម្មនុញ្ញNuremberg (Nuremberg Charter) និងនៅក្នុងច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងបក្សសម្ព័ន្ធលេខ១០ (Allied Control Council Law Number 10)[19] ព្រមទាំងសេចក្តីសម្រេចនានារបស់តុលាការឧក្រិដ្ឋកម្ម

[18] ទាក់ទងនឹងនិយមន័យច្បាប់ទំនៀមទម្លាប់អន្តរជាតិ សូមមើល*North Sea Continental Shelf (រឿងក្តីសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ តទល់នឹង ប្រទេសដាណឺម៉ាក។ រឿងក្តីសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ តទល់នឹង ប្រទេសហូឡង់)* អង្គសេចក្តី ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៦៩ តុលាការយុត្តិធម៌អន្តរជាតិ Rep. ៣ កថាខណ្ឌទី៧៧។

[19] ច្បាប់នេះផ្អែកលើធម្មនុញ្ញNuremberg និងគ្រប់គ្រងការជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាមជាបន្តបន្ទាប់។ ច្បាប់គ្រប់ប្រឹក្សាគ្រប់គ្រងលេខ១០ នៅក្នុង *រាជកិច្ចផ្លូវការនៃក្រុមប្រឹក្សាគ្រប់គ្រងសម្រាប់ប្រទេសអាល្លឺម៉ង់* (១៩៤៦) ភាគ៣ នៅកថាខណ្ឌទី៥០។ ដោយសារតែច្បាប់ក្រុមប្រឹក្សាគ្រប់គ្រប់លេខ១០ ស្វែងរក "ការបង្កើតមូលដ្ឋានច្បាប់ឱ្យដូចគ្នានៅក្នុងប្រទេសអាល្លឺម៉ង់ ដើម្បីធ្វើការកាត់សេចក្តីឧក្រិដ្ឋកម្មសង្គ្រាមនានា" ហេតុដូចនេះមាត្រា១ នៃច្បាប់ បានបញ្ចូលធម្មនុញ្ញរបស់តុលាការ Nuremberg ជា "ផ្នែកសំខាន់មួយ"នៃច្បាប់។ អនុលោមតាមមាត្រា១ គណៈកម្មាធិការយោធាទាំងអស់ (សហរដ្ឋអាមេរិក អង់គ្លេស កាណាដា និងអូស្ត្រាលី) បានអនុម័តបទបញ្ញាកំពុងអនុវត្ត ដោយសម្រេចឱ្យចុងចោទទទួលខុសត្រូវក្រោមគោលការណ៍ "ការប្រព្រឹត្តបទឧក្រិដ្ឋរួម" ចំពោះបទល្មើសដែលប្រព្រឹត្តដោយសមាជិកផ្សេងណាម្នាក់នៃ

សង្គ្រាមក្រោយសង្គ្រាមលោកលើកទី២ បានបង្កើតសហកម្មឧក្រិដ្ឋកម្មរួមជាផ្នែកមួយក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ មុនការបង្កើតនេះ ការទទួលខុសត្រូវចំពោះការចូលរួមប្រព្រឹត្តផែនការរួម មាននៅក្នុងទម្រង់មួយចំនួននៅក្នុងច្បាប់ផ្ទៃក្នុង ឬយុត្តិសាស្ត្ររបស់ប្រទេសប្រព័ន្ធច្បាប់កូមិនឡូ និងប្រព័ន្ធច្បាប់ស៊ីវិលជាច្រើន យ៉ាងហោចណាស់ចាប់តាំងពីសតវត្សទី១៩។ ជាការពិត យុត្តាធិការបច្ចុប្បន្នជាច្រើន ទទួលស្គាល់ទម្រង់នៃការប្រព្រឹត្តរួម មានលក្ខណៈស្រដៀងគ្នានឹងសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទីIII ដូចជាការសមគំនិត[20] ទ្រឹស្តីឃាតកម្មជាយថាហេតុ[21] *ទស្សនៈនៃការពាក់ព័ន្ធផ្នែកព្រហ្មទណ្ឌ (association de malfaiteurs)*[22] និងទ្រឹស្តីនៃការប្រព្រឹត្តរួមផ្សេងៗទៀតជាច្រើន[23]។

---

"អង្គភាព ឬក្រុម"នោះ។ គណៈកម្មាធិការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ *របាយការណ៍ច្បាប់ទី១៥ស្តីពីការជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាម៩២* (១៩៤៩)។

[20] សូមមើល *Pinkerton តទល់នឹង សហរដ្ឋអាមេរិក* 328 U.S. 640 (1946) (បានបង្កើតវិធានPinkerton ដែលអ្នកសមគំនិត អាចត្រូវផ្តន្ទាទោសចំពោះផលវិបាកដែលអាចប្រមើលមើលសមហេតុផលនៃកិច្ចព្រមព្រៀងខុសច្បាប់នោះ)។

[21] ទ្រឹស្តីឃាតកម្មជាយថាហេតុ ដែលត្រូវបានប្រកាសជាដំបូងដោយ Lord Coke នៅឆ្នាំ១៧៩៧ ត្រូវបានយកមកអនុវត្តនៅចក្រភពអង់គ្លេស សហរដ្ឋអាមេរិក ញ៉ូស៊ីឡែន និងអូស្ត្រាលី។ Antonio Cassese *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* (បោះពុម្ពផ្សាយលើកទីពីរ ឆ្នាំ២០០៨) នៅកថាខណ្ឌទី២០២។ វិធានបានកំណត់ឱ្យចុងចោទ "ទទួលខុសត្រូវចំពោះបទល្មើសពីព្រោះបទល្មើសនេះគឺជាផលវិបាកតាមធម្មជាតិនិងអាចនឹងកើតឡើង ដោយជននោះមានចេតនាជួយ ឬលើកទឹកចិត្តបង្កើត។" Wayne LaFave & Austin Scott *ច្បាប់ព្រហ្មទណ្ឌ* (១៩៧២) នៅទំព័រ ៥១៥-៥១៦។

[22] សាស្ត្រាចារ្យ van Sliedregt កត់សម្គាល់ថា ទស្សនទាននៃ"ការចូលរួមប្រព្រឹត្តបទល្មើស" ដែលត្រូវបានប្រើប្រាស់នៅក្នុងប្រទេសបារាំង និងប្រទេសហូឡង់ ដើម្បីដោះស្រាយការប្រើហិង្សារបស់ហ្វូងមនុស្សតាមដោះស្រាយបញ្ហាឱ្យសមហេតុផល "បានលើកទឹកចិត្តអ្នកពង្រាងច្បាប់Nuremberg ឱ្យដាក់ទណ្ឌកម្មលើសមាជិកនៃអ្នករៀបចំប្រព្រឹត្តអំពើឧក្រិដ្ឋ"។ Eliese van Sliedregt "សហកម្មឧក្រិដ្ឋកម្មរួមគឺជាវិធីក្នុងការផ្តន្ទាទោសបុគ្គលចំពោះបទល្មើសប្រល័យពូជសាសន៍" *5 Journal of Intl Crim. J.* 184, 199 (2006)។

[23] ក្រោមក្រមព្រហ្មទណ្ឌឥណ្ឌាឆ្នាំ១៨៦០ បានដាក់ការទទួលខុសត្រូវជាបុគ្គលចំពោះអំពើខុសច្បាប់ ដែលប្រព្រឹត្តដោយបុគ្គលមួយចំនួនក្នុងការជួយជម្រុញក្នុងផែនការរួម។ Walter Morgan និង A.G. MacPherson *ក្រមព្រហ្មទណ្ឌឥណ្ឌា* (XLV, 1860) (London: GC Hay Co. 1861)។ ស្រដៀងគ្នានេះ ផ្នែកទី ៦១(២) នៃក្រមព្រហ្មទណ្ឌកាណាដាឆ្នាំ១៨៩៣ បានដាក់ទណ្ឌកម្មលើបុគ្គល ដែល"បង្កើតចេតនារួមដើម្បីប្រព្រឹត្តអំពើណាមួយដែលមានគោលបំណងខុសច្បាប់" និងផ្តន្ទាទោស "ភាគីនីមួយ ចំពោះគ្រប់បទល្មើសទាំងអស់ដែលប្រព្រឹត្តដោយអ្នកណាម្នាក់ក្នុងចំណោមពួកគេ ក្នុងការប្រព្រឹត្តដើម្បីយកទៅកាត់សេចក្តីនៃគោលបំណងរួមនោះ"។ ផ្នែកទី ២១(២) នៃក្រមព្រហ្មទណ្ឌ R.S.C. 1970, C-34។

១១. នៅក្នុងការផ្តោតការរិះគន់យ៉ាងខ្លាំងរបស់ខ្លួន លើសេចក្តីសម្រេចរឿងក្តី *Tadic* របស់អង្គជំនុំជម្រះតុលាការឧទ្ធរណ៍នៃតុលាការICTY មេធាវីរបស់ជនត្រូវចោទ មិនបានទទួលស្គាល់ចំណុចសំខាន់ៗនៃព្រឹត្តិហេតុទាំងនេះទេ។ ធម្មនុញ្ញNuremberg ច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០ និងយុត្តិសាស្ត្រពាក់ព័ន្ធនានា បានបង្កើតនូវអ្វីដែលអ្នកជំនាញហៅថា "Grotian Moment"។ "Grotian Moment" កើតឡើងនៅពេលមានការវិវត្តន៍ប្រែប្រួល ដែលវិធាន និងទ្រឹស្តីនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិថ្មីលេចឡើងយ៉ាងលឿនខុសពីធម្មតា និងមានការទទួលយកវិធានឬទ្រឹស្តីនោះ[24]។ ការតវ៉ាប្រឆាំងនឹងការរកឃើញនៅក្នុង *រឿងក្តីTadic* ដែលថាសហកម្មឧក្រិដ្ឋកម្មរួមគឺជាផ្នែកច្បាប់ទំនៀមទម្លាប់អន្តរជាតិចាប់តាំងពីរឿងក្តី Nurmberg គឺជាការតវ៉ាផ្អែកលើរឿងក្តីតិចតួចបំផុត ដែលដកចេញពីយុត្តាធិការមួយចំនួនតូចបំផុតដែលមិនបានពិនិត្យល្អិតល្អន់លើបញ្ហានេះ ដោយមិនយកចិត្តទុកដាក់ចំពោះភស្តុតាងរឹងមាំដែលគាំទ្រការរកឃើញរបស់អង្គជំនុំជម្រះតុលាការឧទ្ធរណ៍របស់តុលាការICTY។

១២. គណៈកម្មាធិការច្បាប់អន្តរជាតិរបស់អង្គការសហប្រជាជាតិ បានទទួលស្គាល់ថា ធម្មនុញ្ញ Nuremberg ច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០ និងការជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាមក្រោយសង្គ្រាមលោកលើកទី២ (រឿងក្តីចំនួនដប់ត្រូវបានដកស្រង់ដាក់ក្នុង *រឿងក្តីTadic*) បានបង្កើត

[24] Hugo Grotius ត្រូវបានគេចាត់ទុកជា "បិតា" នៃច្បាប់អន្តរជាតិ ដែលជាច្បាប់របស់ប្រជាជាតិ និងត្រូវបានទទួលស្គាល់ចំពោះ "ការកត់ត្រាអំពីការបង្កើតរបៀបរៀបរយឲ្យជៀសផុតពីចលាចលនៅក្នុងវិស័យដ៏ធំនៃទំនាក់ទំនងអន្តរ-ជាតិ"។ សូមមើល CHARLES S. EDWARDS, HUGO GROTIUS, THE MIRACLE OF HOLLAND (១៩៨១)។ ពាក្យ "Grotian Moment" ត្រូវបានបង្កើតឡើងដោយ Burns H. Weston នៅក្នុងសៀវភៅច្បាប់អន្តរជាតិ, ច្បាប់អន្តរជាតិ និងរបៀបរៀបរយពិភពលោក, ១៣៦៩ (បោះពុម្ពលើកទី៣ ឆ្នាំ១៩៩៧)។ សូមមើលផងដែរ Saul Mendlovitz & Marev Datan *ចៅក្រម Weeramantry"s Grotian Quest, 7 transnational L. & CONTEP. PROBS. 401, 402* (បានឲ្យនិយមន័យពាក្យ "Grotian moment")។ Ibrahim J. Gassama, *International Law at a Grotian Moment: បរិបទនៃការឈ្លានពានរបស់ប្រទេសអ៊ីរ៉ាក់,* 18 EMORY INTL L. REV. 1, 9 (2004) (រៀបរាប់អំពីប្រវត្តិ Grotian moments រួមមានសន្តិភាពនៅWestphalia ធម្មនុញ្ញ Nuremberg និងធម្មនុញ្ញអង្គការសហប្រជាជាតិ)។ Leila Nadya Sadat, *តុលាការព្រហ្មទណ្ឌអន្តរជាតិថ្មី៖ បដិវត្តន៍ពិបាកមួយ,* 88 GEORGTOWN L. J. 381, 474 (បញ្ជាក់ថា លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិបង្កើតនៅGrotian moment ថ្មីៗជាងគេ)។

ជាគំរូអន្តរជាតិចំពោះការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបុគ្គល[25]។ សំខាន់ជាងនេះ កាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៤៦ សកម្មភាពមួយក្នុងចំណោមសកម្មភាពដំបូងបង្អស់របស់អង្គការសហប្រជាជាតិដែលទើបនឹងបង្កើតថ្មី មហាសន្និបាតអង្គការសហប្រជាជាតិបានបញ្ជាក់ច្បាស់លាស់ជាឯកច្ឆន្ទលើគោលការណ៍ធម្មនុញ្ញNuremberg និងសេចក្តីសម្រេចរបស់តុលាការNuremberg[26]។ សកម្មភាពនេះបានបញ្ជាក់ច្បាស់ថា ទាំងច្បាប់សារធាតុ និងទ្រឹស្តីនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបុគ្គល (រួមមាន ការទទួលខុសត្រូវ "ផែនការរួម") ដែលចែងនៅក្នុងធម្មនុញ្ញNuremberg និងដែលតុលាការ Nuremberg បានយកមកអនុវត្ត គឺជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ជាផលវិបាក ការទទួលខុសត្រូវផែនការរួម (ដែលហៅថា សហកម្មឧក្រិដ្ឋកម្មរួម) ត្រូវបានគេដាក់ជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដូចគ្នានឹងទស្សនៈជាសារវ័ន្តនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាអន្តរជាតិ ដែលមាននៅក្នុងគោលការណ៍Nuremberg ដែល អ.វ.ត.ក យកមកអនុវត្តដែរ។ ទស្សនៈទាំងនេះរួមមាន៖ ការទទួលខុសត្រូវរបស់ថ្នាក់លើ គោលការណ៍នៃការគោរពតាមបញ្ជារបស់ថ្នាក់លើមិនអាច

[25] សូមមើល *របាយការណ៍របស់គណៈកម្មាធិការច្បាប់អន្តរជាតិស្តីពីការងារសម័យប្រជុំលើកទីសែបសិបប្រាំបី* ថ្ងៃទី៦ ខែឧសភា រហូតដល់ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ កំណត់ហេតុផ្លូវការរបស់មហាសន្និបាត, សម័យប្រជុំលើកទីហាសិបមួយ, សេចក្តីបន្ថែមលេខ១០ នៅទំព័រ១៩ ដែលអាចរកតាមគេហទំព័រ http://www.un.org/law.ilc/index.htm (រៀបរាប់អំពីគោលការណ៍នៃការទទួលខុសត្រូវជាបុគ្គល និងការដាក់ទណ្ឌកម្មចំពោះបទល្មើសក្រោមច្បាប់អន្តរជាតិ ដែលទទួលស្គាល់នៅតុលាការ Nuremberg ថាជា "មូលដ្ឋានច្បាប់ព្រហ្មទណ្ឌអន្តរជាតិ" និង "វក្សានីត្យានុកូលរបស់ធម្មនុញ្ញ និងសេចក្តីសម្រេចរបស់តុលាការ Nuremberg"។)

[26] ការបញ្ជាក់អះអាងគោលការណ៍ច្បាប់អន្តរជាតិ ដែលទទួលស្គាល់ដោយធម្មនុញ្ញរបស់តុលាការNuremberg, G.A. Res. 95 (I), UN GAOR, 1st Sess., pt. 2 at 1144, U.N. Doc A/236 (1946)។ សេចក្តីសម្រេចចិត្តដែលបញ្ជាក់អំពីគោលការណ៍របស់Nuremberg ណែនាំគណៈកម្មាធិការច្បាប់អន្តរជាតិរបស់អង្គការសហប្រជាជាតិដើម្បីចងក្រងគោលការណ៍ទាំងនេះនៅក្នុងក្រមអន្តរជាតិនៃបទល្មើសប្រឆាំងនឹងសន្តិភាពនិងសន្តិសុខមនុស្សជាតិ។ សេចក្តីព្រាងក្រមដំបូងរបស់គណៈកម្មាធិការច្បាប់អន្តរជាតិនៅឆ្នាំ១៩៥៦ បានរួមបញ្ចូលយ៉ាងច្បាស់ "នូវគោលការណ៍ទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គលចំពោះការរៀបចំផែនការ ឬចូលរួមប្រព្រឹត្តក្នុងផែនការរួម ឬការសមគំនិតដើម្បីប្រព្រឹត្តបទល្មើសមួយ" (មាត្រា២ កថាខណ្ឌទី១៣ (i))។ សូមមើល *របាយការណ៍របស់គណៈកម្មាធិការច្បាប់អន្តរជាតិស្តីពីការងាររបស់សម័យប្រជុំលើកទីសែសិបប្រាំបី* នៅថ្ងៃទី៦ ខែឧសភា រហូតដល់ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ កំណត់ហេតុផ្លូវការរបស់មហាសន្និបាត សម័យប្រជុំលើកទីហាសិបមួយ សេចក្តីបន្ថែមលេខ ១០ នៅទំព័រទី២១ ដែលអាចរកតាមគេហទំព័រ http://www.un.org/law.ilc/index.htm.

យកជាសម្អាងដើម្បីការពារខ្លួន ទស្សនៈដាក់ការទទួលខុសត្រូវចំពោះបទល្មើសអន្តរជាតិលើមេដឹកនាំទោះបីជាពួកគេមានតួនាទីជាមន្ត្រីក្តី និងទស្សនៈដែលថាវីត្រូវទទួលខុសត្រូវចំពោះការប្រព្រឹត្តិដែលនាំឲ្យមានបទល្មើសក្រោមច្បាប់អន្តរជាតិ ថ្វីបើច្បាប់ក្នុងស្រុកមិនបានចែងអំពីការផ្តន្ទាទោសចំពោះការប្រព្រឹត្តិនេះក្តី។

១៣. នៅក្នុងពេលដាក់សេចក្តីព្រាងច្បាប់របស់តុលាការICTY ជូនក្រុមប្រឹក្សាសន្តិសុខ នាឆ្នាំ១៩៩៣ អគ្គលេខាធិការអង្គការសហប្រជាជាតិបានគូសបញ្ជាក់អំពីគោលការណ៍ និងវិធានរបស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលកើតចេញមកពីតុលាការNuremberg និងយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី២ផ្សេងៗទៀត។ ជាពិសេស អគ្គលេខាធិការបានថ្លែងថា ច្បាប់លក្ខន្តិកៈបានព្រាងដើម្បីអនុវត្តត្រឹមតែ "វិធានច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលហួសពីវិមតិសង្ស័យថាជាផ្នែកមួយរបស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ" ដែលរួមមានច្បាប់សារធាតុ និងទម្រង់នៃការទទួលខុសត្រូវដែលមានចែងនៅក្នុង "ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិកាលពីថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៤៥"[27]។ ផ្ទុយនឹងទឡ្ហីករណ៍ដែលលើកឡើងនៅកថាខណ្ឌទី៥៤ក្នុងសេចក្តីអង្កេតបន្ថែម សេចក្តីថ្លែងការណ៍ឆ្នាំ១៩៩៣ ស្តីពីអត្ថន័យរបស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក៏បានបញ្ជាក់ភាពត្រឹមត្រូវនៃពេលវេលារបស់បទល្មើស ចំពោះមុខតុលាការនេះ (១៩៧៥-១៩៧៩) ដោយសារគ្មានបម្រែបម្រួលសំខាន់ផ្សេងទៀត នៃចំណុចនេះនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិក្នុងចន្លោះរវាងឆ្នាំ១៩៧៥ និងពេលបង្កើតតុលាការICTY ឆ្នាំ១៩៩៣។ ដូចបានលើកឡើងនៅក្នុងឯកសាររបស់ Ciara Damgaard "ប្រភពនៃទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួមអាចត្រូវបានរកឃើញនៅក្នុងអំឡុងពេលក្រោយសង្គ្រាមលោកលើកទី២"[28]។

១៤. ទឡ្ហីករណ៍ដែលលើកឡើងនៅក្នុងសេចក្តីអង្កេតបន្ថែម (ពិសេសនៅកថាខណ្ឌទី៥៤) មិនបានទទួលស្គាល់ភាពចាំបាច់នៃសេចក្តីថ្លែងបញ្ជាក់ឆ្នាំ១៩៤៦ និងសេចក្តីថ្លែងការណ៍ឆ្នាំ១៩៩៣

---

27 របាយការណ៍របស់អគ្គលេខាធិការអនុលោមតាមមាត្រា២នៃសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខលេខ៨០៨ (១៩៩៣) កថាខណ្ឌទី៣៤ និងទី៣៥។

28 Ciara Damgaard, *ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលចំពោះបទល្មើសអន្តរជាតិសំខាន់ៗ* ឆ្នាំ២០០៨ ទំព័រ១៣២។

របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលជាភស្តុតាងយ៉ាងច្បាស់បញ្ជាក់ថាវាជាច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ។ សម្អាងរបស់ជនត្រូវចោទអំពី រឿងក្តីឧក្រិដ្ឋកម្មសង្គ្រាមក្រោយសង្គ្រាមលោកលើកទី២ ដែលប្រើប្រាស់ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម"មានចំនួនតិចតួច" គឺជាសម្អាងមិនត្រឹមត្រូវទេ។ សហកម្មឧក្រិដ្ឋកម្មរួមគឺជាបដិវេលខជាសកល និងមិនមានលក្ខខណ្ឌចំពោះគោលការណ៍Nuremberg តាំងពីដើមឆ្នាំ១៩៤៦។ ផ្ទុយទៅវិញវាមិនមែនជាចំនួនរឿងក្តីដែលបានអនុវត្តការទទួលខុសត្រូវ សហកម្មឧក្រិដ្ឋកម្មរួមនៅពេលនោះ ដែលបានបង្កើតទ្រឹស្តីនេះក្នុងទម្រង់នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គលក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ[29]។ វាមិនសមស្របទេ ប្រសិនបើ "អ.វ.ត.កមិនអាចប្រើប្រាស់របាយការណ៍របស់ អគ្គលេខាធិការដើម្បីជាជំនួយដល់អង្គបុរេជំនុំជម្រះក្នុងការសម្រេចថាតើសហកម្មឧក្រិដ្ឋកម្មរួមជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះ"[30]។ ច្បាប់ទំនៀមទម្លាប់ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ឆ្នាំ១៩៩៣ របស់អគ្គលេខាធិការ ពិតជាអាចយកមកអនុវត្តនៅចំពោះមុខតុលាការនេះបាន[31]។

១៥. ដោយស្របគ្នានឹងប្រភពនៃទ្រឹស្តីនៅក្នុងកិច្ចព្រមព្រៀងអន្តរជាតិ (ធម្មនុញ្ញNuremberg) និងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិ "សហកម្មឧក្រិដ្ឋកម្មរួមគឺជាការលាយបញ្ចូលគ្នារវាងច្បាប់កុម្មុនឡ និងច្បាប់ស៊ីវិល។ សហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងច្បាប់អន្តរជាតិគឺជាទស្សនាទានតែមួយគត់ *(sui generis)* ដែលផ្សំចូលគ្នារវាងវប្បធម៌និងប្រព័ន្ធច្បាប់ពីរ"[32]។ វាមិនចម្លែកអ្វីទេ ដែលថា ឈ្មោះ"សហកម្មឧក្រិដ្ឋកម្មរួម" មិនបានរកឃើញនៅក្នុងការអនុវត្តរបស់

---

[29] សូមមើល Frank Lawrence, *គោលការណ៍Nuremberg៖ ការការពារខ្លួនចំពោះអ្នកគាំទ្រផ្នែកនយោបាយ* 40 *Hastings L. J.* 397, 408-410 (1989) (បញ្ហាកើតមានចំពោះទឡ្ហីករណ៍ដែលលើកឡើងថា "ចំនួនព្រឹត្តិការណ៍លើសពីមួយគឺជាការចាំបាច់សម្រាប់គោលការណ៍លើកឡើងដើម្បីចាត់ទុកគោលការណ៍នោះថាជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ")។

[30] សេចក្តីអង្កេតបន្ថែម កថាខណ្ឌទី៥៤។

[31] សូមមើលផងដែរ ទឡ្ហីករណ៍ខាងក្រោមក្នុងផ្នែកទី៣ ទាក់ទងនឹងការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅអ.វ.ត.ក។

[32] Elies van Sliedregt, សហកម្មឧក្រិដ្ឋកម្មរួមជាវិធីក្នុងការផ្តន្ទាទោសបុគ្គលពីបទល្មើសប្រល័យពូជសាសន៍ 5 *J. Int'l Crim. Just.* 184, 199 (2007)។

រដ្ឋ ដោយសារតែទម្រង់ នៃការទទួលខុសត្រូវទាំងបីតំណាងឱ្យការសំយោគរវាងយុត្តាធិការផ្សេងៗទៀត។ ជាពិសេស ប្រទេសមហាអំណាច បានកំពុងស្វែងរកការបង្កើតវិធីសាស្ត្រនៅក្នុងធម្មនុញ្ញNuremberg ដែលលាយបញ្ចូលគ្នាទ្រឹស្តីការសមគំនិតរបស់ប្រព័ន្ធច្បាប់អាមេរិក (Anglo-American) ជាមួយនឹងវិធីសាស្ត្រនៅក្នុងប្រទេសបារាំង និងសហភាពសូវៀតដែលការសមគំនិតមិនត្រូវបានគេចាត់ទុកជាបទល្មើសទេ[33]។ ដូច្នេះ មាត្រា៦ នៃធម្មនុញ្ញឡុងដុង (London Charter) (លក្ខន្តិកៈរបស់តុលាការNuremberg) បានអនុវត្តទម្រង់កែប្រែថ្មីនៃសំណើផ្តួចផ្តើមរបស់អាមេរិកដើម្បីរួមបញ្ចូលបទសមគំនិត ដែលបានចែងថា "មេដឹកនាំ អ្នករៀបចំ អ្នកញុះញង់ និងអ្នកសមគំនិត ដែលចូលរួមក្នុងការរៀបចំ ឬ *ប្រព្រឹត្តផែនការរួម* ឬសមគំនិតដើម្បីប្រព្រឹត្តបទល្មើសដែលនឹងកើតឡើង ជនទាំងនោះត្រូវទទួលខុសត្រូវចំពោះអំពើទាំងអស់ដែលប្រព្រឹត្តដោយបុគ្គលណាមួយក្នុងការប្រតិបត្តិផែនការនោះ"[34]។

១៦. ក្នុងអំឡុងពេលជំនុំជម្រះនៅNuremberg ចៅក្រមRobert Jackson ដែលជាប្រធានអ្នកចរចាធម្មនុញ្ញNuremberg និងជាប្រធានរដ្ឋអាជ្ញាសហរដ្ឋអាមេរិកនៅNuremberg បានពន្យល់តុលាការអំពីអត្ថន័យរបស់ "ផែនការរួម" ដែលមានសញ្ញាណខុសគ្នាពីបទសមគំនិតរបស់សហរដ្ឋអាមេរិក៖

> ធម្មនុញ្ញមិនបានឱ្យនិយមន័យអំពីការទទួលខុសត្រូវចំពោះអំពើរបស់អ្នកផ្សេង នៅក្នុងករណី "សមគំនិត"តែមួយប៉ុណ្ណោះទេ។ បទល្មើសត្រូវបានគេកំណត់ន័យដោយការប្រើពាក្យពេជន៍សាមញ្ញប៉ុន្តែរួមបញ្ចូលគ្រប់ទាំងអស់ និងក្តោបទាំងការរៀបចំនិងការប្រតិបត្តិ "ផែនការរួម" ព្រមទាំងការចូលរួមក្នុង "ការសមគំនិត"។ វាគឺជាការគួរឱ្យបារម្ភថា ការអនុវត្តផ្សេងពីនេះអាចបណ្តាលឱ្យមានលក្ខខណ្ឌនិងដែនកំណត់បច្ចេកទេសរបស់ដំណើរការនីតិវិធី ដែលបានកើតឡើងញឹកញាប់ចំពោះការ ប្រើពាក្យ "ការសមគំនិត" រួចមកហើយ។ ភាពខុសគ្នាមួយ

[33] Stanslaw Pomorski, ការសមគំនិត និងអង្គការបទឧក្រិដ្ឋ *ការជំនុំជម្រះនៅNuremberg និងច្បាប់អន្តរជាតិ* 213, 216 (George Ginsburgs & V.N. Kudriavtsev eds., 1990)។

[34] កិច្ចព្រមព្រៀងសម្រាប់ការយកទៅកាត់ទោស និងការផ្តន្ទាទោសលើទាហានជាន់ខ្ពស់អាល្លឺម៉ង់ ពីបទឧក្រិដ្ឋកម្មសង្គ្រាមលើសម្ព័ន្ធមិត្តអឺរ៉ុប មាត្រា៦, 59 Stat. 1544, 82 U.N.T.S. 279។

ចំនួន កើតមានរវាងទស្សនការសមគំនិតក្នុងប្រព័ន្ធនិយមអាមេរិក (Anglo-American) និង ទស្សនសមគំនិតក្នុងយុត្តិសាស្ត្ររបស់ប្រទេសសូវៀត ប្រទេសបារាំង ឬប្រទេសអាល្លឺម៉ង់។ យើងត្រូវតែមានរឿងក្តីជាក់លាក់ដើម្បីធ្វើការណែនាំ ដោយមានការពិចារណាជាប់ជាមួយនឹង លក្ខណៈនៃបញ្ហាសង្គម ជាជាងការគ្រប់គ្រងតាមរយៈបង្កើតច្បាប់ក្នុងស្រុកណាមួយ[35]។

១៧. ដោយស្របទៅតាមសេចក្តីថ្លែងការណ៍នេះ តុលាការ Nuremberg[36] និងច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០ បានទទួលយកទស្សនៈ "ផែនការរួម"ក្នុងទម្រង់របស់ខ្លួន ហេតុដូចនេះបាន កែប្រែ "ផែនការរួម"ឱ្យក្លាយទៅជាអ្វីដែលគេស្គាល់ថាជាទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម។ តុលាការទាំងនេះបានរកឃើញថា "ភាពខុសគ្នារវាងការចោទប្រកាន់ពីបទសមគំនិត និងបទល្មើស ដែលកើតឡើងដោយសារផែនការរួម គឺថាបទសមគំនិតនឹងត្រូវបានគេចោទថាជាកិច្ចព្រមព្រៀង ដែលធ្វើឡើងដើម្បីប្រព្រឹត្តបទល្មើស ប៉ុន្តែចំពោះករណីបទល្មើសដែលកើតឡើងដោយសារ ផែនការរួម ត្រូវបានគេចោទប្រកាន់មិនត្រឹមតែការធ្វើកិច្ចព្រមព្រៀងដើម្បីប្រព្រឹត្តបទល្មើស ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការប្រព្រឹត្តិបទល្មើសនានាដែលកើតឡើងទាក់ទងនឹង "កិច្ចព្រមព្រៀងនោះ"[37]។ និយាយម្យ៉ាងទៀត បទសមគំនិតគឺជាបទល្មើសដែលទទួលខុសត្រូវតែក្នុង កិច្ចព្រមព្រៀងរបស់ខ្លួន ប៉ុន្តែការប្រព្រឹត្តិទាក់ទងនឹងផែនការរួមឬគម្រោងរួម ដូចសហកម្ម ឧក្រិដ្ឋកម្មរួម គឺជាទម្រង់ទទួលខុសត្រូវដែលជាប់ទាក់ទងនឹងបទល្មើសសារធាតុនានា។ ក្នុង ការបង្កើតទម្រង់នៃការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួម ដែលចេញពីវិធីសាស្ត្រដែលមាន នៅក្នុងយុត្តិសាស្ត្ររបស់ប្រទេសនានា តុលាការ Nuremberg បានប្រកាសនូវសេចក្តី សន្និដ្ឋានរបស់ខ្លួនថា "អនុលោមតាមគោលការណ៍ច្បាប់យ៉ាងត្រឹមត្រូវ ដែលក្នុងគោលការណ៍

---

[35] Robert H. Jackson, ច្បាប់ដែលអង្គការNazi ត្រូវបានចោទប្រកាន់ជាឧក្រិដ្ឋជន, តវ៉ាដោយRobert H. Jackson នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៤៦ បោះពុម្ពនៅក្នុង *រឿងក្តីNurnberg៖ដូចបង្ហាញជូនដោយ Robert Jackson, 1971, ទំព័រ ១០៨។*

[36] *សូមមើល* សេចក្តីសម្រេចរបស់តុលាការយោធាអន្តរជាតិ, ក្នុងការជំនុំជម្រះយោធាជាន់ខ្ពស់ពីបទឧក្រិដ្ឋកម្មសង្គ្រាម ចំពោះមុខតុលាការយោធាអន្តរជាតិ, Nuremberg ភាគ១ ឆ្នាំ១៩៤៧ ទំព័រ២២៦។

[37] *របាយការណ៍ច្បាប់លើកទី១៥ ស្តីពីការជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាម ៩៧-៩៨,* គណៈកម្មាធិការឧក្រិដ្ឋកម្មសង្គ្រាមរបស់ អង្គការសហប្រជាជាតិ ឆ្នាំ១៩៤៨ (ការសង្ខេបយុត្តិសាស្ត្ររបស់Nuremberg និងតុលាការរបស់ច្បាប់ក្រុមប្រឹក្សា គ្រប់គ្រងលេខ១០)។

សំខាន់បំផុតមួយគឺថា កំហុសព្រហ្មទណ្ឌគឺជាកំហុសផ្ទាល់ខ្លួនរបស់បុគ្គល និងគួរតែជៀសវាងចំពោះការដាក់ទណ្ឌកម្មជាទ្រង់ទ្រាយធំ”[38]។

១៨. នៅពេលតុលាការ Nuremberg ក្នុងការជំនុំជម្រះសមាជិកនៅរស់ថ្នាក់ខ្ពស់បំផុតនៃរបប Nazi ចំនួន២២នាក់ ប្រទេសមហាអំណាចបក្សសម្ព័ន្ធបានរួមគ្នាប្រកាសឱ្យប្រើច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០ ដើម្បីគ្រប់គ្រងការជំនុំជម្រះជាបន្តបន្ទាប់លើជនសង្ស័យជនជាតិអាល្លឺម៉ង់ដែលប្រព្រឹត្តបទល្មើស ក្នុងអំឡុងពេលគេកាន់អំណាច នៅប្រទេសអាល្លឺម៉ង់ ដែលការជំនុំជម្រះនឹងធ្វើឡើងដោយតុលាការយោធារបស់ប្រទេសអាមេរិក ប្រទេសកាណាដា និងប្រទេសអូស្ត្រាលី។ ក្រោមអំណាចនៃច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០ តុលាការយោធាទាំងនេះ ត្រូវតែអនុវត្តតាមធម្មនុញ្ញ និងយុត្តិសាស្ត្ររបស់តុលាការ Nuremberg[39]។ ហេតុដូចនេះ យុត្តិសាស្ត្រពីតុលាការទាំងនោះ ត្រូវបានចាត់ទុកថាជាការបកស្រាយតាមអាជ្ញាព្រឹត្តនៃធម្មនុញ្ញ និងសេចក្តីសម្រេចនៅ Nuremberg និងបង្ហាញឱ្យឃើញជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ[40]។

១៩. ការវិភាគលើរឿងក្តីមួយចំនួនរបស់ច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០ បានគាំទ្រសេចក្តីសន្និដ្ឋានថា ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម ត្រូវបានតុលាការទាំងនោះប្រើប្រាស់នៅឆ្នាំ១៩៤៦-

---

[38] តុលាការយោធាអន្តរជាតិ, សេចក្តីសម្រេច, នៅក្នុងការជំនុំជម្រះសង្គ្រាមធំៗចំពោះមុខតុលាការយោធាអន្តរជាតិ៖ Nuremberg, ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៤៥ រហូតដល់ថ្ងៃទី១ ខែតុលា ឆ្នាំ១៩៤៧ ទំព័រ២៥៦។

[39] ច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០ នៅក្នុង *រាជកិច្ចផ្លូវការនៃក្រុមប្រឹក្សាគ្រប់គ្រងសម្រាប់ប្រទេសអាល្លឺម៉ង់ ឆ្នាំ១៩៤៦* vol. 3, p. 50។

[40] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kupreskic,* សំណុំរឿងលេខ IT-95-16-A, អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការICTY សេចក្តីសម្រេច ថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ កថាខណ្ឌទី៥៤១៖ “យើងមិនអាចបដិសេធថា តម្លៃសំខាន់គួរតែភ្ជាប់ទៅនឹងសេចក្តីសម្រេចរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិដូចជាតុលាការអន្តរជាតិNuremberg និងតូក្យូ ឬតុលាការជាតិតាមការប្រតិបត្តិដោយគុណធម៌ និងដោយប្រើកម្លាំង, ច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០, ច្បាប់ដោយអនុម័តរួមគ្នានៅក្នុងឆ្នាំ១៩៤៥ដោយប្រទេសមហាអំណាចទាំងបួន និងការឆ្លុះបញ្ចាំងកិច្ចព្រមព្រៀងអន្តរជាតិក្នុងចំណោមប្រទេសមហាអំណាចស្តីពីច្បាប់សម្រាប់អនុវត្តបទល្មើសអន្តរជាតិ និងយុត្តាធិការរបស់តុលាការលើកឡើងដើម្បីសម្រេចលើបទល្មើសទាំងនេះ។ តុលាការទាំងនេះប្រតិបត្តិក្រោមលិខិតុបករណ៍អន្តរជាតិ ដែលមានចែងក្នុងបទប្បញ្ញត្តិថា យើងអាចប្រកាសជាច្បាប់ដែលចូលជាធរមាន ឬជាការបំលែងបន្តិចម្តងទៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ”។

១៩៤៧។ ក្នុងការចេញសម្រេចរបស់ខ្លួនអំពីអត្ថិភាពសហកម្មឧក្រិដ្ឋកម្មរួម *រឿងក្តីTadic* បានផ្អែកមួយផ្នែកលើរឿងក្តីក្រោយសង្គ្រាមលោកលើកទី២ផ្សេងៗចំនួនដប់ ដែលរឿងក្តីចំនួនប្រាំមួយទាក់ទងនឹងសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទីI[41] រឿងក្តីចំនួនពីរទាក់ទងនឹងសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទីII[42] និងរឿងក្តីចំនួនពីរទាក់ទងនឹងសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទីIII[43]។ រឿងក្តីទាំងនេះភាគច្រើនត្រូវបានគេបោះពុម្ពផ្សាយនៅក្នុងទម្រង់សង្ខេប នៅក្នុងរបាយការណ៍របស់គណៈកម្មាធិការបទល្មើសសង្គ្រាមរបស់អង្គការសហប្រជាជាតិឆ្នាំ១៩៤៩[44]។ បន្ថែមលើរឿងក្តីចំនួនដប់ខាងលើនេះ សហព្រះរាជអាជ្ញាបានរកឃើញរឿងក្តីចំនួនដប់ប្រាំមួយផ្សេងទៀត ដែលបោះពុម្ពផ្សាយនៅក្នុងរបាយការណ៍ របស់គណៈកម្មាធិការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិឆ្នាំ១៩៤៩ និងរបាយការណ៍របស់តុលាការសហរដ្ឋអាមេរិកសម្រាប់ឧក្រិដ្ឋកម្មសង្គ្រាមនៅ Nuremberg ដែលតុលាការនានានៃច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០ បានអនុវត្តនូវទ្រឹស្តីផែនការរួម ឬគម្រោងរួម/សហកម្មឧក្រិដ្ឋកម្មរួម[45]។

---

[41] Otto Sandrock និងអ្នកផ្សេងៗបីនាក់ទៀត។ Hoelzer et al។ Gustav Alfred Jepsen និង អ្នកផ្សេងទៀត។ Franz Schonfeld និងអ្នកផ្សេងទៀត។ Feurstein និងអ្នកផ្សេងទៀត។ Otto Ohlenforf et al។

[42] *រឿងក្តីជំរុំប្រមូលផ្តុំ Dachau* (ការជំនុំជម្រះ Martin Gottfied Weiss និងអ្នកផ្សេងសាមសិបប្រាំបួននាក់ទៀត) និង *រឿងក្តីBelsen* (ការជំនុំជម្រះ Josef Kramer និងអ្នកផ្សេងសែសិបបួននាក់ទៀត)។

[43] *រឿងក្តី Essen Lynching, រឿងក្តី Borkum Island*។ ចំពោះសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣ អង្គជំនុំជម្រះតុលាការកំពូលបានដកស្រង់សេចក្តីសម្រេចរបស់អ៊ីតាលីមួយចំនួនដែលមិនបានបោះពុម្ពផ្សាយ។

[44] គួរឱ្យកត់សម្គាល់ សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣ *នៃរឿងក្តីBorkum Island* មិនមានដាក់បញ្ចូលនៅក្នុងរបាយការណ៍របស់គណៈកម្មាធិការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ ប៉ុន្តែលិខិតុបករណ៍ចោទប្រកាន់ ប្រតិចារិក និងឯកសារផ្សេងទៀតរបស់រឿងក្តី ត្រូវបានបោះពុម្ពផ្សាយជាសាធារណៈពីបណ្ណសាររបស់អង្គការសហប្រជាជាតិ។ សូមមើល ការបោះពុម្ពផ្សាយលេខ M1103 "កំណត់ហេតុអំពីការជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាមរបស់កងទ័ពសហរដ្ឋអាមេរិក, *សហរដ្ឋអាមេរិក តទល់នឹង Goebel និងអ្នកផ្សេងទៀត* ថ្ងៃទី៦ ខែកុម្ភៈ រហូតដល់ថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៤៦។ បន្ថែមពីលើនេះ ការរៀបរាប់លម្អិត និងការវិភាគ *រឿងក្តីBorkun Island* បានបោះពុម្ពផ្សាយនៅឆ្នាំ១៩៥៦ នៅក្នុង Maxilimian Koessler *សោកនាដកម្ម និងការជំនុំជម្រះBorkum Island, ព្រឹត្តិប័ត្រច្បាប់ព្រហ្មទណ្ឌលេខ៤៧* ១៨៣-១៩៦ (១៩៥៦)។

[45] *ការជំនុំជម្រះ Heinz និងជនបួននាក់ផ្សេងទៀត,* តុលាការយោធាអង់គ្លេសសម្រាប់ការសេចក្តីឧក្រិដ្ឋកម្មសង្គ្រាម នៅ Hamburg ប្រទេសអាល្លឺម៉ង់ ថ្ងៃទី១៧-២០ ខែតុលា ឆ្នាំ១៩៤៥, គណៈកម្មាធិការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ, របាយការណ៍ច្បាប់ស្តីពីឧក្រិដ្ឋកម្មសង្គ្រាម ភាគ១ ទំព័រ១-២១ (១៩៤៧)។ *ការជំនុំជម្រះAlfons*

00268539



*Klein និងជនប្រាំមួយនាក់ផ្សេងទៀត* គណៈកម្មាធិការយោធាសហរដ្ឋអាមេរិក តែងតាំងដោយអគ្គបញ្ជាការយោធាស្រុកប៉ែកខាងលិច នៅ Wiesbaden អាល្លឺម៉ង់ ថ្ងៃទី៨-១៥ ខែតុលា ឆ្នាំ១៩៤៥ នៅក្នុងគណៈកម្មាធិការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ, របាយការណ៍ច្បាប់ស្តីពីការជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាម ភាគទី១ ទំព័រ ៤៦-៥៤ (១៩៤៧)។ *ការជំនុំជម្រះErich Killinger និងបួននាក់ផ្សេងទៀត* តុលាការយោធាអង់គ្លេស នៅ Wuppertal អាល្លឺម៉ង់ ថ្ងៃទី២៦ ខែវិច្ឆិកា រហូតដល់ថ្ងៃទី៣ ខែធ្នូ ឆ្នាំ១៩៤៥ គណៈកម្មាធិការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ, របាយការណ៍ច្បាប់ស្តីពីការជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាម ភាគទី៣ ទំព័រ ៦៧-៧៤ (១៩៤៨)។ *ការជំនុំជម្រះKarl Buck និងជនដប់នាក់ផ្សេងទៀត* តុលាការយោធាអង់គ្លេសសម្រាប់ជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាម នៅ Wuppertal អាល្លឺម៉ង់ ថ្ងៃទី៦-១០ ខែមិថុនា ឆ្នាំ១៩៤៦ គណៈកម្មាធិការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ, របាយការណ៍ច្បាប់ស្តីពីការជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាម ភាគទី៥ ទំព័រ៣៩-៤៤ (១៩៤៨)។ *ការជំនុំជម្រះKarl Adam Golkel និងជនដប់បីនាក់ផ្សេងទៀត* តុលាការយោធាអង់គ្លេសសម្រាប់ជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាម នៅ Wuppertal អាល្លឺម៉ង់ ថ្ងៃទី៦-១០ ខែមិថុនា ឆ្នាំ១៩៤៦ គណៈកម្មាធិការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ, របាយការណ៍ច្បាប់ស្តីពីការជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាម ភាគទី៥ ទំព័រ៤៥-៥៣ (១៩៤៨)។ *ការជំនុំជម្រះWerner Rohde និងជនប្រាំបីនាក់ផ្សេងទៀត* តុលាការយោធាអង់គ្លេសសម្រាប់ជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាម នៅ Wuppertal អាល្លឺម៉ង់ ថ្ងៃទី៦-១០ ខែមិថុនា ឆ្នាំ១៩៤៦ គណៈកម្មាធិការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ, របាយការណ៍ច្បាប់ស្តីពីការជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាម ភាគទី៥ ទំព័រ ៥៤-៥៩ (១៩៤៨)។ *ការជំនុំជម្រះJosef Altstotter និងអ្នកផ្សេងទៀត* តុលាការយោធាសហរដ្ឋអាមេរិក ថ្ងៃទី១៧ ខែកុម្ភៈ -ថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៤៧ គណៈកម្មាធិការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ, របាយការណ៍ច្បាប់ស្តីពីការជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាម ភាគទី៦ ទំព័រ១-១១០ (១៩៤៨)។ *ការជំនុំជម្រះHeinrich Gericke និងជនប្រាំពីរនាក់ផ្សេងទៀត* តុលាការយោធាអង់គ្លេស នៅ Brunswick ថ្ងៃទី២០ ខែមីនា-ថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៤៦ គណៈកម្មាធិការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ, របាយការណ៍ច្បាប់ស្តីពីការជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាម ភាគទី៣ ទំព័រ ៧៦-៨១ (១៩៤៨)។ *ការជំនុំជម្រះCarl Krauch និងជន២២នាក់ផ្សេងទៀត* តុលាការយោធាសហរដ្ឋអាមេរិក Nuremberg ថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៤៧-ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៤៨ គណៈកម្មាធិការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ, របាយការណ៍ច្បាប់ស្តីពីការជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាម ភាគទី១០ ទំព័រ១-៦៨។ *ការជំនុំជម្រះ Alfried Felix Alwyn Krupp Von Bohlen Und Halbach និងជនដប់មួយនាក់ផ្សេងទៀត* តុលាការយោធាសហរដ្ឋអាមេរិក Nuremberg ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤៧-ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៤៨ គណៈកម្មាធិការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ, របាយការណ៍ច្បាប់ស្តីពីការជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាម ភាគទី១០ ទំព័រ៦៩-១៨១។ *ការជំនុំជម្រះMax Wielen និងជនដប់ប្រាំពីរនាក់ផ្សេងទៀត* តុលាការយោធាអង់គ្លេស នៅ Hamburg អាល្លឺម៉ង់ ថ្ងៃទី១ ខែកក្កដា-ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៤៧ គណៈកម្មាធិការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ, របាយការណ៍ច្បាប់ស្តីពីការជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាម ភាគទី១១ ទំព័រ៣១-៥៣ (១៩៤៩)។ *ការជំនុំជម្រះHans Renoth និងជនបីនាក់ផ្សេងទៀត* តុលាការយោធាអង់គ្លេសសម្រាប់ជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាម នៅ Elden អាល្លឺម៉ង់ ថ្ងៃទី៨-១០ ខែមករា ឆ្នាំ ១៩៤៦ គណៈកម្មាធិការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ, របាយការណ៍ច្បាប់ស្តីពីការជំនុំជម្រះឧក្រិដ្ឋកម្ម

00268540



ថ្មីៗនេះ បណ្ណាល័យ អ.វ.ត.ក ទើបបានទទួលសំណុំរឿងចំនួនដប់ពីតុលាការអាល្លឺម៉ង់ដែលបានអនុវត្តទ្រឹស្តីផែនការរួម/សហកម្មឧក្រិដ្ឋកម្មរួម ដោយអនុលោមតាមយុត្តាធិការរបស់ច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០ លើឧក្រិដ្ឋជនអាល្លឺម៉ង់ដែលចោទប្រកាន់ពីបទឧក្រិដ្ឋកម្មសង្គ្រាម[46]។ រឿងក្តីទាំងអស់នេះបានបញ្ជាក់ពីអត្ថន័យនៃការទទួលខុសត្រូវលើផែនការរួមរបស់ Nuremberg ដែលពេលបច្ចុប្បន្ននេះត្រូវបានគេស្គាល់ថាជាសហកម្មឧក្រិដ្ឋកម្មរួម។ តាមការសរុបច្បាប់យុត្តិសាស្ត្រដ៏ទូលំទូលាយនេះ និងការរៀបរាប់អំពីភាពខុសគ្នារវាងផែនការរួម និងការប្រព្រឹត្តិរួមក្នុងទម្រង់ធម្មតា របាយការណ៍របស់គណៈកម្មាធិការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិបានថ្លែងថា “ការចោទប្រកាន់ត្រូវមានការបង្ហាញឱ្យឃើញបន្ថែមអំពីអត្ថិភាពនៃផែនការរួម [និង] នៅពេលអត្ថិភាពត្រូវបានបង្ហាញ ការចោទប្រកាន់អាចផ្អែកលើវិធានដែលមាននៅក្នុងប្រព័ន្ធជាច្រើននៃច្បាប់ ដែលជនទាំងឡាយណាចូលរួមក្នុងផែនការរួមដើម្បីប្រព្រឹត្តបទល្មើសដែលប្រព្រឹត្តដោយជនម្នាក់ក្នុងចំណោមនោះ ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះបទល្មើសនោះដោយអនុលោមតាមច្បាប់ព្រហ្មទណ្ឌ”[47]។ ស្របគ្នាតាមការបកស្រាយនេះ និងក្រោយពីពិចារណាសារណាជាច្រើនដែលដាក់ដោយភាគីនានាទាក់ទងនឹងបញ្ហាថាតើសហកម្មឧក្រិដ្ឋកម្មរួមជាផ្នែកមួយរបស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ អង្គជំនុំជម្រះ

---

សង្គ្រាម ភាគទី១១ ទំព័រ៧៦-៧៨ (១៩៤៩)។ *ការជំនុំជម្រះEberhard Schoengrath និងជនប្រាំមួយនាក់ផ្សេងទៀត* តុលាការយោធាអង់គ្លេសសម្រាប់ជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាម នៅBurgsteinfurt អាល្លឺម៉ង់ ថ្ងៃទី៧-១១ ខែកុម្ភៈ ឆ្នាំ ១៩៤៦ គណៈកម្មាធិការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ, របាយការណ៍ច្បាប់ស្តីពីការជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាម ភាគទី១១ ទំព័រ៨៣-៨៥ (១៩៤៩)។

[46] តុលាការច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០ (តុលាការថ្នាក់ស្រុករបស់អាល្លឺម៉ង់ ) នៃតំបន់គ្រប់គ្រងរបស់អង់គ្លេស, StS 11/50 ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ១៩៥០, StS 356/49 ថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៥០, StS 31/50 ថ្ងៃទី១៥ ខែសីហា ឆ្នាំ ១៩៥០, StS 156/49 ថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩៤៩, StS 130/49 ថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៥០, StS 287/49 ថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៤៩, StS 177/49 ថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៤៩, StS 256/49 ថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៥០, StS 256 និង 257/49 ថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៥០, StS 514/49 ថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៥០។ គ្រប់ការផ្តន្ទាទោសទាំងអស់ត្រូវបានតំកល់ដោយតុលាការកំពូលអាល្លឺម៉ង់ នៃតំបន់កាន់កាប់ដោយអង់គ្លេស។ ឯកសារថតចម្លងជាភាសាអាល្លឺម៉ង់ ទាំងស្រុងនៃរឿងក្តីទាំងនេះមាននៅក្នុងសំណុំឯកសារនៅបណ្ណាល័យអ.វ.ត.ក។

[47] គណៈកម្មាធិការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ, របាយការណ៍ច្បាប់ស្តីពីការជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាម, UNWCC, ភាគទី១៥ (១៩៤៨) ទំព័រ៩៦។

តុលាការឧទ្ធរណ៍របស់តុលាការ ICTY *នៅក្នុងរឿងក្ដី Milutinovic* បានរកឃើញថា សហកម្មឧក្រិដ្ឋកម្មរួម និងការទទួលខុសត្រូវផែនការរួមមានលក្ខណៈដូចគ្នា[48]។

២០. ដោយពិនិត្យឃើញថា សេចក្ដីអង្កេតបន្ថែម ផ្ដោតលើសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទីIII, រឿងក្ដីចំនួនបីរបស់ច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០ ដែលដោះស្រាយលើទម្រង់នៃការទទួលខុសត្រូវលើសហកម្មឧក្រិដ្ឋកម្មរួម ត្រូវបានសង្ខេបដូចខាងក្រោម។ ការជំនុំជម្រះលើករណី Erich Heyer និងជនប្រាំមួយនាក់ផ្សេងទៀត ដែលរឿងក្ដីនេះមានឈ្មោះថា *Essen Lynching* គឺជាឧទាហរណ៍មួយ។ រឿងក្ដីនេះ ត្រូវបានលើកឡើងនៅក្នុងសេចក្ដីអង្កេតបន្ថែមនានា ទោះបីជាគេផ្ដោតរួមលើតែចុងចោទម្នាក់ក៏ដោយ (គឺចុងចោទ Heyer) ក្នុងចំណោមចុងចោទទាំងអស់។ យោងតាមសេចក្ដីសង្ខេបផ្លូវការនៃការជំនុំជម្រះ ដែលបានបោះពុម្ពផ្សាយនៅក្នុងរបាយការណ៍ របស់គណៈកម្មាធិការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ, រឿងក្ដីនេះពាក់ព័ន្ធនឹងឃាតកម្មលើឈ្លើយសឹកសង្គ្រាមអង់គ្លេសបីរូប ដោយក្រុមអាល្លឺម៉ង់[49]។ ទោះបីរឿងក្ដីនេះ ត្រូវបានជំនុំជម្រះដោយតុលាការយោធាអង់គ្លេសក៏ដោយ ការជំនុំជម្រះបានធ្វើឡើង អនុលោមតាមយុត្តាធិការនៃច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ ១០។ ដូច្នេះ ការជំនុំជម្រះនេះ "មិនមែនជាការជំនុំជម្រះ អនុលោមតាមច្បាប់អង់គ្លេសឡើយ"។ ជនជាប់ចោទមួយរូបក្នុងចំណោមជនជាប់ចោទទាំងឡាយ គឺលោកអនុសេនីយ៍ឯក Heyer បានឱ្យទាហានអាល្លឺម៉ង់ម្នាក់ឈ្មោះ Koenen បណ្ដើរអ្នកទោសបីរូប។ ទាហានរូបនេះ នាំឈ្លើយសឹកទាំងបីទៅសួរចម្លើយ។ នៅពេលដែល Koenen បានចាកចេញ, Heyer ដោយឮសម្លេងហ្វូងមនុស្សដែលកំពុងរង់ចាំ បានបង្គាប់មិនឱ្យ Koenen ចូលអន្តរាគមន៍ ប្រសិនបើជនស៊ីវិលអាល្លឺម៉ង់ យាយីផ្លូវភេទលើឈ្លើយសឹកទាំងនោះ ហើយ Heyer បាននិយាយថា ឈ្លើយសឹកទាំងនេះ សមតែគេបាញ់សម្លាប់ចោល និងប្រហែលជាគេយកទៅបាញ់សម្លាប់ចោល។ ហ្វូងមនុស្សនោះបានវាយដំលើឈ្លើយសឹក ហើយនាយទាហានអាល្លឺម៉ង់ម្នាក់បានយកកាំភ្លើងខ្លីរ៉ុលវែរបាញ់អ្នកទោសម្នាក់របួសត្រង់ក្បាល។ អ្នកទោសម្នាក់បានស្លាប់ភ្លាមៗ នៅពេលដែលពួក

[48] សេចក្ដីសម្រេចMilutinovic កថាខណ្ឌទី៣៦។

[49] *ការជំនុំជម្រះErich Heyer និងជនប្រាំមួយនាក់ផ្សេងទៀត* តុលាការយោធាអង់គ្លេសសម្រាប់ជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាម នៅEssen ថ្ងៃទី១៨-១៩ និងថ្ងៃទី២១-២២ ខែធ្នូ ឆ្នាំ១៩៤៥, UNWCC, ភាគទី១ (១៩៤៩) កថាខណ្ឌទី៨៨។

គេត្រូវបានគេចាប់បោះចុះពីលើស្ពាន ហើយអ្នកទោសពីរនាក់ទៀតដែលមិនទាន់ស្លាប់ ត្រូវបានគេបាញ់សម្លាប់ពីលើស្ពាន និងត្រូវបានវាយដំដោយសមាជិកនៃហ្វូងមនុស្សមួយក្រុមនោះរហូតដល់ស្លាប់។ តុលាការមិនបានទទួលយកទឡ្ហីករណ៍របស់ក្រុមការពារក្តីដែលថា អយ្យការចាំបាច់ត្រូវបង្ហាញថា ជនជាប់ចោទម្នាក់ៗ គឺ Heyer, Koenen និងជនស៊ីវិលប្រាំរូបទៀត មានចេតនាសម្លាប់ឈ្លើយសឹកនោះទេ។ អយ្យការបានផ្តល់ទឡ្ហីករណ៍ថា ដើម្បីកាត់ឱ្យជាប់ទោស, ជនជាប់ចោទ ត្រូវតែ"ពាក់ព័ន្ធនឹងការស្លាប់របស់ឈ្លើយសឹកបីរូបនោះ" ហើយវាដូចគ្នាទៅនឹងការកាត់ឱ្យជាប់ទោសចំពោះជនជាប់ចោទជាជនស៊ីវិលទាំងបីរូបទៀត ក្នុងចំណោមជនទាំងប្រាំរូបនោះ។ ទោះបីមិនមានការបង្ហាញថា ជនស៊ីវិលណាមួយជាអ្នកបង្កការបាញ់សម្លាប់ ឬការវាយដំរហូតដល់ស្លាប់, ពួកគេត្រូវបានកាត់ឱ្យជាប់ទោស ពីព្រោះ "ចាប់ពីពេលដែលពួកគេចាកចេញពីបន្ទាយទាហាន ឈ្លើយសឹកត្រូវបានគេធ្វើបាប និងហ្វូងមនុស្សបានដឹងថា ឈ្លើយសឹកត្រូវបានគេធ្វើបាប ដូច្នេះអ្នករាល់គ្នានៅក្នុងហ្វូងនោះដែលប្រព្រឹត្តការវាយដំ គឺត្រូវទទួលខុសត្រូវទាំងផ្នែកសីលធម៌ និងព្រហ្មទណ្ឌ ចំពោះការស្លាប់របស់បុរសឈ្លើយសឹកបីនាក់នោះ"[50]។

២១. ការជំនុំជម្រះនៃរឿងក្តី *Hans Renoth និងបុគ្គលបីរូបទៀត*[51] គឺជាឧទាហរណ៍ទីពីរ។ ឧទាហរណ៍នេះមិនបានដកស្រង់នៅក្នុងរឿងក្តី *Tadic* ដែលគណៈកម្មាធិការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ យល់ឃើញថាស្រដៀងនឹងរឿងក្តី *Essen Lynching*។ នៅក្នុងរឿងក្តីនេះ មន្ត្រីនគរបាលពីររូប (គឺ Hans Ronoth និង Hans Pelgrim) និងមន្ត្រីគយពីររូបទៀត (គឺ Friedrich Grabowski និង Paul Neike) បានត្រូវគេចោទប្រកាន់ថាបានប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាមមួយ។ នៅក្នុងឧក្រិដ្ឋកម្មនោះ ពួកគេបាន"ពាក់ព័ន្ធនឹងការសម្លាប់អ្នកបើកយន្តហោះសម្ព័ន្ធមិត្ត ដែលគេមិនស្គាល់ឈ្មោះ ហើយជននោះគឺជាឈ្លើយសឹកសង្គ្រាម"។ តាមបទចោទប្រកាន់ អ្នកបើកយន្តហោះរូបនេះ បានបើកយន្តហោះធ្លាក់លើដែនដីអាល្លឺម៉ង់

---

50 *ដូចខាងលើដែរ* ទំព័រ៩៧។

51 *ការជំនុំជម្រះHans Ronoth និងជនបីនាក់ផ្សេងទៀត* តុលាការយោធាអង់គ្លេស ថ្ងៃទី៩-១០ ខែមករា ឆ្នាំ១៩៤៦, UNWCC, ភាគទី១៥ (១៩៤៩) កថាខណ្ឌទី៧៦-៧៧។

ដោយមិនមានរបួសទេ។ ហើយគាត់ត្រូវបានចាប់ខ្លួនដោយ Renoth។ បន្ទាប់មក គាត់ទទួលរងការវាយប្រហារ និងការវាយតប់ ដោយកណ្តាប់ដៃ និងកាំភ្លើងវែង ពីសំណាក់ក្រុមមនុស្សជាច្រើន ខណៈពេលដែលចុងចោទបីរូបទៀត បានឃើញជាក់ស្តែងនូវការវាយតប់នោះ ប៉ុន្តែមិនបានចាត់វិធានការសកម្មណាមួយ ដើម្បីបញ្ឈប់ ឬជួយអ្នកបើកយន្តហោះរូបនោះ។ Renoth ក៏ឈរនៅទីនោះ មួយភ្លែតផងដែរ ហើយបន្ទាប់មកបាញ់សម្លាប់អ្នកបើកបរយន្តហោះនោះចោល។ "រឿងក្តីចំពោះការចោទប្រកាន់គឺថា មានគម្រោងរួមមួយ ដែលនៅក្នុងនោះ ជនជាប់ចោទបួនរូប បានចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម [ហើយ] ជនជាប់ចោទទាំងបួន បានដឹងអំពីគម្រោងរួមនេះ ហើយជនទាំងបួនរូបនេះ បានប្រព្រឹត្ត ដើម្បីសម្រេចគម្រោងនេះ"[52]។ ជនជាប់ចោទទាំងអស់ ត្រូវបានគេរកឃើញពិរុទ្ធភាព តាមការសន្មតលើភាពអាចប្រមើលមើលឃើញថា នៅទីបំផុត អ្នកបើកបរយន្តហោះ នឹងត្រូវបានគេសម្លាប់ក្នុងពេលវាយតប់ដោយដៃរបស់ហ្វូងមនុស្ស ឬដោយបុគ្គលណាម្នាក់នៅក្នុងហ្វូងនោះ។

២២. សំណុំរឿងក្តីរបស់ *Kurt Goebell et. Al* (សំណុំរឿងក្តី *Borkum ISland*) គឺជាឧទាហរណ៍ទីបី។ ទោះបីជាសំណុំរឿងក្តីនេះមិនចុះផ្សាយនៅក្នុងរបាយការណ៍របស់អង្គការសហប្រជាជាតិស្តីពីការប្រព្រឹត្តិឧក្រិដ្ឋកម្មសង្គ្រាម (Report of the UN War Crimes Commission) ក៏ដោយ ក៏កំណត់ហេតុលំអិតរបស់រឿងក្តីនេះមាន បោះពុម្ពជាហ្វីល (Microfilm) នៅក្នុងបណ្ណសារជាតិសហរដ្ឋអាមេរិក សម្រាប់បម្រើតាមសេចក្តីត្រូវការរបស់សាធារណជនផងដែរ[53]។ លើសពីនេះទៅទៀត របាយការណ៍សវនាការនៃសំណុំរឿងក្តីនេះក៏ចុះផ្សាយលំអិត (ដោយយោងទៅប្រតិចារឹកនៃអង្គសវនាការ) នៅក្នុង*ព្រឹត្តិបត្រ ស្រាវជ្រាវច្បាប់ព្រហ្មទណ្ឌ*

---

[52] *ដូចខាងលើដែរ* កថាខណ្ឌទី៧៦។

[53] បណ្ណសាររបស់សហរដ្ឋអាមេរិច ចុះផ្សាយលេខ M1103 "កំណត់ហេតុសវនាការពីឧក្រិដ្ឋកម្មសង្គ្រាមរបស់កងទ័ពអាមេរិច *សហរដ្ឋអាមេរិច v. Goebell* និងតួអង្គផ្សេងៗទៀត ថ្ងៃទី៦ ខែកុម្ភៈ - ថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៤៦។ អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងសំណុំរឿងក្តី *Tadic* បានលើកឡើងថា ច្បាប់ចម្លងសំណុំឯកសាររឿងក្តីនេះ មានរក្សាទុកនៅក្នុងបណ្ណាល័យរបស់ ICTY. សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿងក្តីរបស់ Tadic ទំព័រ ៨៣។

*(Journal of Criminal Law)* ក្នុងឆ្នាំ១៩៥៦ ផងដែរ[54]។ យោង តាមរបាយការណ៍នោះ ចៅហ្វាយក្រុង Borkum និងមន្ត្រីយោធា និងទាហានអាល្លឺម៉ង់ជាច្រើនរូបទៀត ត្រូវបានផ្តន្ទាទោសពីបទប្រើកម្លាំងរំលោភ និងសម្លាប់អាកាសយានិកសញ្ជាតិអាមេរិកកាំងចំនួនប្រាំពីរនាក់ ដែលបានបញ្ហាអាកាសយានចុះចតក្នុងពេលមានអាសន្ន។ តំណាងអយ្យការបានលើកឡើងថា ជនជាប់ចោទសុទ្ធតែជា "ចំណែកមួយនៃផែនការរួម ដែលមានមុខងារសំខាន់ដូចៗគ្នា ដោយម្នាក់ៗបំពេញមុខងារ ទៅតាមអ្វីដែលគេបានចាត់ចែងឲ្យខ្លួនបំពេញ"។ តំណាងអយ្យការបានបន្តលើកឡើងទៀតថា "វាបានបញ្ជាក់យ៉ាងច្បាស់ដោយគ្មានការសង្ស័យអ្វីទាល់តែសោះថា ជនជាប់ចោទម្នាក់ៗ សុទ្ធតែបានចូលរួមនៅក្នុងការប្រើអំពើហិង្សាជាក្រុម ដែលបណ្តាលឲ្យកើតមានការសម្លាប់មនុស្សក្រៅច្បាប់" ដូច្នេះ "តាមច្បាប់ ជនជាប់ចោទគ្រប់ៗរូបត្រូវជាប់ពិរុទ្ធពីបទធ្វើមនុស្សឃាត"។ បន្ទាប់ពីបានពិភាក្សាសម្រេចជាសម្ងាត់រួចមក ចៅក្រមបានចេញសាលក្រមមួយ ដោយសម្រេចចោទប្រកាន់ចៅហ្វាយក្រុង និងមន្ត្រីមួយចំនួនទៀត ពីបទសម្លាប់មនុស្ស និងប្រើកម្លាំងរំលោភបំពាន។ ទឡ្ហីករណ៍ និងភស្តុតាងដែលបានដាក់ជូនបង្ហាញយ៉ាងជាក់ស្តែងណាស់ថា ជនជាប់ចោទទាំងនោះមានពិរុទ្ធភាព ដោយអនុលោមទៅតាមទម្រង់ នៃផែនការទទួលខុសត្រូវរួម ដែលមានលក្ខណៈដូចគ្នាទៅនឹងទម្រង់ទី៣ នៃសហកម្មឧក្រិដ្ឋកម្មរួមដែរ។ ជាពិសេស តុលាការបានសម្រេចថា ទោះបីជាចុងចោទមួយចំនួនមិនបានចូលរួមប្រព្រឹត្តឃាតកម្ម និងគ្មានចេតនាឲ្យឃាតកម្មកើតឡើងយ៉ាងណាក៏ដោយ ក៏ពួកគេត្រូវតែទទួលខុសត្រូវដែរ ព្រោះផលវិបាក នៃការប្រព្រឹត្តិរបស់ពួកគេទៅលើអ្នកទោសទាំងនោះ ជាផលវិបាក ដែលអាចប្រមើលទុកជាមុន និងទៅតាមដំណើរជាធម្មតា។

២៣. ដោយយោងទៅលើចរិតលក្ខណៈបទឧក្រិដ្ឋអន្តរជាតិ និងទារុណកម្មយង់ឃ្នងទៅលើហ្វូងមនុស្សនោះ ដោយយោងទៅលើសនិទានកម្មនៃអត្ថិភាពរបស់សហកម្មឧក្រិដ្ឋកម្មរួម និងដោយយោងទៅលើភាពមិនសូវមានសវនាការពីបទឧក្រិដ្ឋបែបនេះកើតមាននោះ ដូច្នេះវាមិនមានអ្វីគួរឲ្យភ្ញាក់ផ្អើលចំពោះការពិត ដែលថាមានឧទាហរណ៍តែមួយចំនួនតិចតួចប៉ុណ្ណោះ ដែលពាក់

---

[54] Maxilimian Koessler, សោកនាដកម្មនៅកោះ *Borkum* និងសវនាការរបស់សំណុំរឿងនេះ ចុះផ្សាយក្នុង *ទស្សនាវដ្តីច្បាប់ឧក្រិដ្ឋកម្ម* ទំព័រ ១៨៣ -១៩៦ (១៩៥៦)។

ព័ន្ធនឹងយុត្តិសាស្ត្រជាតិ ដែលបានអនុវត្តទម្រង់នានានៃការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួម។ លើសពីនេះទៅទៀត វាក៏គ្មានឧទាហរណ៍ណាមួយដែលអាចលើកយកមកផ្ទុះបញ្ចាំងពីទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម ដូចបានពិភាក្សាពីខាងដើមរួចមកហើយថា សហកម្មឧក្រិដ្ឋកម្មរួមជាទ្រឹស្តីដែលសំយោគចេញពីវិធីសាស្ត្រនានា ដែលដកស្រង់ចេញពីច្បាប់កូមិនឡូ និងច្បាប់ស៊ីវិល។ ទោះបីជានៅក្នុងរយៈពេលសង្គ្រាមត្រជាក់ មានសវនាការតែមួយចំនួនតូចទាក់ទងនឹងឧក្រិដ្ឋកម្មសង្គ្រាមជាតិក៏ដោយ ប៉ុន្តែនៅក្នុងសេចក្តីសម្រេចរបស់តុលាការ Jerusalem District Court និងសេចក្តីសម្រេចរបស់តុលាការកំពូលនៅ Israel ក្នុង*សំណុំរឿងក្តី Eichmann* បានបង្ហាញថា គិតត្រឹមឆ្នាំ១៩៦១ តុលាការជាតិនានា បានទទួលស្គាល់រួចទៅហើយចំពោះសហកម្មឧក្រិដ្ឋកម្មរួម ដែលបានវិវឌ្ឍន៍ទៅតាមច្បាប់ និងយុត្តិសាស្ត្រនានាក្រោយពីសង្គ្រាមលោកលើកទីពីរបានបញ្ចប់[55]។ វិធីសាស្ត្ររបស់តុលាការ Jerusalem District ក្នុងការកំណត់ការទទួលខុសត្រូវដោយឡែករបស់ Adolf Eichmann ក្នុងការចូលរួមប្រព្រឹត្តផែនការឧក្រិដ្ឋកម្មរួម ដើម្បីសម្លាប់ជនជាតិ Jew នៅអឺរ៉ុបឱ្យផុតពូជ មានលក្ខណៈស្រដៀងទៅនឹងវិធីសាស្ត្រដែលអនុវត្តដោយច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ ក្នុងសំណុំរឿងក្តីនានា ដូចបានដកស្រង់ពីខាងលើ (ការដកស្រង់ ភាគច្រើនគឺយកចេញពីសេចក្តីសម្រេចរបស់តុលាការ Jerusalem District)។ វិធីសាស្ត្រ ដែលបានយកមកអនុវត្តនោះ មានបញ្ជាក់យ៉ាងច្បាស់នៅក្នុងសេចក្តីថ្លែងការណ៍នេះតែម្តង៖

> ដោយហេតុនេះ ជនទាំងឡាយណាដែលបានចូលរួមក្នុងសកម្មភាពសម្លាប់ជនជាតិជូរអ៊ីស (Jew) ដែលបានដឹងពីផែនការដំណោះស្រាយចុងក្រោយ និងការវិវត្តនៃផែនការនោះ នឹងត្រូវចាត់ទុកជាជនសមគំនិតក្នុង ការបរិសុទ្ធទៅលើមនុស្សរាប់លាននាក់ ដែលត្រូវបានគេសម្លាប់នៅក្នុងរយៈពេលពីឆ្នាំ១៩៤១-១៩៤៥ ដោយមិនចាំបាច់ពិចារណាទៅលើអង្គហេតុ ថាតើសកម្មភាពរបស់បុគ្គលនោះបង្កឱ្យមានការសម្លាប់ទាំងស្រុងកើតឡើង ឬបង្កឱ្យមានការសម្លាប់ចំពោះតែមួយផ្នែក ឬច្រើនផ្នែកនៃការសម្លាប់នោះទេ។ ជននោះត្រូវតែទទួលខុសត្រូវក្នុងឋានៈជា "ជនដែលបង្កោល" ដែលបានប្រព្រឹត្ត

---

[55] *អគ្គរដ្ឋអាជ្ញា* របស់ *Israel v. Eichmann*, 36 I.L.R.5 (ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៦១) [*បន្ទាប់ពីនេះទៅហៅថា* Eichmann] បញ្ជាក់ដោយ អគ្គរដ្ឋអាជ្ញារបស់ *Israel v. Eichmann*, 36 I.L.R. 277 (ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៦២)។

បទឧក្រិដ្ឋទាំងស្រុងដោយបានរួមសហការជាមួយនឹងជនផ្សេងៗទៀត[56]។

តុលាការ District Court យល់ឃើញថា Eichmann បានដឹងពីផែនការឧក្រិដ្ឋក្នុងការសម្លាប់ជនជាតិជ្វីហ្វ នៅខែមិថុនា ឆ្នាំ១៩៤១។ គាត់បានចូលរួមយ៉ាងសកម្មបន្តអនុវត្តផែនការនេះ តាមរយៈការប្រតិបត្តិតួនាទីដ៏សំខាន់របស់គាត់ជា ជនបង្គោល សម្រាប់កិច្ចការជនជាតិជ្វីហ្វ នៅក្នុងការិយាល័យសន្តិសុខ Reich ក្នុងដើមខែសីហា ឆ្នាំ១៩៤១។ គាត់មានចេតនាទុកជាមុន (ចេតនាជាក់ច្បាស់ ព្រោះគោលដៅរបស់ផែនការនោះ គឺអំពើប្រល័យពូជសាសន៍) ក្នុងការបន្តអនុវត្តផែនការ ដូចមានបង្ហាញជាភស្តុតាងក្នុង "សភាពដ៏ទូលំទូលាយនៃវិសាលភាពរបស់សកម្មភាពគាត់" ដែលបានប្រព្រឹត្តទៅក្នុងគោលបំណងសម្រេចឱ្យបាននូវការសម្លាប់ជនជាតិជ្វីហ្វផ្តាច់ពូជ[57]។ ដោយផ្អែកលើមូលដ្ឋាន នៃការរកឃើញដូចនេះ Eichmann ត្រូវទទួលខុសត្រូវបទឧក្រិដ្ឋទាក់ទង "បទឧក្រិដ្ឋទូទៅ" នៃសេចក្តីសម្រេចចុងក្រោយ ដែលរួមបញ្ចូលទាំងអំពើ ដែលបង្កឱ្យមានបទឧក្រិដ្ឋ "ដែលគាត់បានបំពេញតួនាទីក្នុងផ្នែក ដែលស្ថិតក្រោមការទទួលខុសត្រូវរបស់គាត់យ៉ាងសកម្ម *និងនៅក្នុងសកម្មភាពនានាដែលអ្នកចូលរួមសមគំនិតជាមួយគាត់បានប្រព្រឹត្តក្នុងផ្នែកផ្សេងៗ នៃបទឧក្រិដ្ឋក្នុងគោលដៅតែមួយ*[58]"។ ដោយប្រកាន់ជំហរបែបនេះ តុលាការ District Court បានសម្រេចថាការបានដឹងឮទាំងស្រុងអំពីវិសាលភាព នៃការអនុវត្តផែនការគឺជាការមិនចាំបាច់ទេ ដោយកត់សម្គាល់ថា ជនដែលជាបង្គោលជាច្រើនអាចមានការយល់ដឹង តែផ្នែកខ្លះៗប៉ុណ្ណោះ ហើយមិនបានយល់ដឹងអំពីផែនការទាំងមូលនោះទេ[59]។ តុលាការកំពូលរបស់ប្រទេស Israle បានដកស្រង់សេចក្តីសម្រេចរបស់អង្គមហាសន្និបាតក្នុងឆ្នាំ១៩៤៦ ដែលបញ្ជាក់ពីគោលការណ៍ Nuremberg ដែលបានចែងថា៖ "ប្រសិនបើមានការព្រមព្រៀង ជាឯកច្ឆន្ទ ទៅលើសេចក្តីថ្លែងការណ៍ស្តីពីច្បាប់ដែលមានជាធរមានពីប្រទេសទាំង៥៨ នោះហាក់បីដូចជាបានសេចក្តីថាការប្រកាសទទួលស្គាល់ច្បាប់ដែលមានជាធរមាននោះពុំមានន័យអ្វី ក្រៅអំពីថា វាជាភស្តុតាង

---

[56] Eichmann កថាខណ្ឌ ១៩៥។

[57] ដូចឯកសារយោងពីខាងដើម កថាខណ្ឌ ១៨២។

[58] ដូចឯកសារយោងពីខាងដើម កថាខណ្ឌ ១៩៧ (បញ្ជាក់បន្ថែម)។

[59] ដូចឯកសារយោងពីខាងដើម កថាខណ្ឌ ១៩៣។

ឯកឆន្ទ នៃការទទួលស្គាល់ច្បាប់ជាធរមាន ហើយការព្រមព្រៀងគ្នា ដោយមតិភាគច្រើនបែប នេះ ផ្តល់តម្លៃយ៉ាងពិសេស ក្នុងការកំណត់អំពីច្បាប់ជាធរមាន”[60]។

២៤. មានបញ្ហាមួយពាក់ព័ន្ធនឹងចម្ងល់ ថាតើច្បាប់យុត្តិសាស្ត្រ ទាំងមុននិងក្រោយ Nuremberg ជាច្បាប់យុត្តិសាស្ត្រ ដែលអាចអនុវត្តបានឬមិនបាន ដោយហេតុថាច្បាប់យុត្តិសាស្ត្រទាំងនោះ បានកើតឡើងក្នុងអំឡុងពេល ដែលមានជម្លោះប្រដាប់អាវុធអន្តរជាតិ។ ICTY យល់ឃើញថា សហកម្មឧក្រិដ្ឋកម្មរួម អាចយកមកអនុវត្តបានចំពោះបទឧក្រិដ្ឋអន្តរជាតិ ដោយមិនបែងចែក ថាជម្លោះប្រភេទណានោះទេ[61]។ ស្រដៀងគ្នានេះដែរ ហេតុផលដែល ICTR បានប្រើក្នុង ការបដិសេធនៅក្នុង*សំណុំរឿងក្តី Karamera* ដែលមានលក្ខណៈប្លែកពីគេនោះ អាចយកមក ធ្វើជាប្រយោជន៍ក្នុងការពិចារណាបាន៖

> ស្ថានទម្ងន់ក្នុងការចូលរួមប្រព្រឹត្តសហកម្មឧក្រិដ្ឋកម្មរួម មិនអាស្រ័យទៅលើចរិតលក្ខណៈនៃជម្លោះ នោះទេ។ លើសពីនេះទៅទៀត ដូចអង្គជំនុំជម្រះតុលាការឧទ្ធរណ៍ (ករណី *Tadic*) បានប្រកាន់យក ដោយអំណាចរបស់ខ្លួនថា រចនាសម្ព័ន្ធបទឧក្រិដ្ឋអន្តរជាតិតម្រូវឲ្យត្រូវតែអនុវត្តការទទួលខុសត្រូវ ចំពោះសហកម្មឧក្រិដ្ឋកម្មអន្តរជាតិ ដើម្បីធានាប្រសិទ្ធភាព នៃការជំនុំជម្រះក្តី។ អង្គជំនុំជម្រះយល់ ឃើញថា គ្មានភាព ខុសគ្នាអ្វីសោះរវាងរចនាសម្ព័ន្ធរបស់បទឧក្រិដ្ឋជាតិ និងបទឧក្រិដ្ឋអន្តរជាតិ ដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលដែលកើតមានជម្លោះប្រដាប់អាវុធអន្តរជាតិនោះទេ។ ដូច្នេះ ហេតុផលដដែល ដែល អង្គជំនុំជម្រះតុលាការឧទ្ធរណ៍បានប្រើនៅក្នុងសំណុំរឿងក្តី *Tadic* ត្រូវតែយក មកអនុវត្តប្រកបដោយ សមភាពចំពោះជម្លោះប្រដាប់អាវុធជាតិនានា។ ចរិតលក្ខណៈនៃជម្លោះ ក៏មិនពាក់ព័ន្ធនឹងការទទួល ខុសត្រូវរបស់ចារីដែរ។ លក្ខណៈវិនិច្ឆ័យនេះអាចប្រើប្រាស់បានចំពោះតែ បទឧក្រិដ្ឋដែលមានលក្ខណៈសំគាល់ជាក់លាក់មួយចំនួនប៉ុណ្ណោះ មិនសំដៅទៅលើការទទួលខុស

---

[60] *អគ្គរដ្ឋអាជ្ញារបស់ Israel v. Eichmann,* 36 I.L.R 277 (ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៦២) កថាខណ្ឌ១១ (ទាក់ទងនឹងយុត្តិសាស្ត្រសកលសម្រាប់បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ) កថាខណ្ឌ ១៤ (ទាក់ទងការជំទាស់នៃទង្វើ របស់មេធាវីការពាររដ្ឋ) និងកថាខណ្ឌ ១៥ (ទាក់ទងការជំទាស់របស់មេធាវីការពារមេបញ្ជា)។

[61] *អយ្យការ v. Prlic,* សំណុំរឿងក្តីលេខ. IT-04-74-PT, សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង II នៅ ICTY ក្នុងការច្រានចោលការបដិសេធបឋមជំទាស់នឹងយុត្តាធិការរបស់សាលាក្តី, ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៥ កថាខណ្ឌ ២០។

ត្រូវរបស់ជនដែលអាចនឹងជាចារី របស់សកម្មភាពដែលត្រូវបានចោទប្រកាន់នោះទេ[62]។

២៥. ដោយហេតុថាទម្រង់ទាំងបីរបស់សហកម្មឧក្រិដ្ឋកម្មរួម មានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងពេលដែលបទឧក្រិដ្ឋកើតមានក្នុងយុត្តាធិការរបស់តុលាការនេះ (១៩៧៥-១៩៧៩) ការពិភាក្សាជាបន្តទៅនេះ ពាក់ព័ន្ធនឹងការកំនត់ ថាតើជាក់ស្តែងទ្រឹស្តីនេះអាចយកមកអនុវត្តនៅអ.វ.ត.ក បានដែរឬយ៉ាងណា។

## ខ. ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួមអាចយកមកប្រើប្រាស់បាននៅអ.វ.ត.ក

២៦. សហព្រះរាជអាជ្ញាបានលើកឡើងថា ចុងចោទរបស់តុលាការនេះ បានដឹងឮគ្រប់គ្រាន់ហើយថា ការចូលរួមរបស់ពួកគេនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម នឹងតម្រូវឱ្យពួកគេទទួលខុសត្រូវចំពោះរាល់សកម្មភាពដែលបានប្រព្រឹត្តមកនោះ។ ការដឹងឮគ្រប់គ្រាន់គឺជាលក្ខខណ្ឌទីពីររបស់គោលការណ៍នីត្យានុកូលភាព (*គោលការណ៍គ្មានច្បាប់គឺគ្មានទោស*) នឹងគ្រប់គ្រាន់សម្រាប់ធ្វើឱ្យសហកម្មឧក្រិដ្ឋកម្មរួមអាចយកទៅអនុវត្តបាននៅក្នុងអ.វ.ត.ក។ លើសពីនេះទៅទៀត ទម្រង់នៃការទទួលខុសត្រូវបែបនេះមានចែងដោយផ្ទាល់ ឬដោយប្រយោលក្នុងលិខិតូបករណ៍របស់តុលាការរួចស្រេចទៅហើយ។ ផ្នែកនេះនឹងធ្វើការពិភាក្សាទៅលើបញ្ហាទាំងពីរនេះ មុននឹងពិភាក្សាអំពីទឡ្ហីករណ៍ នៅក្នុងសេចក្តីអង្កេតបន្ថែម ដែលថាច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនអាចយកមកអនុវត្តនៅក្នុងតុលាការកម្ពុជាបាន ហើយក៏មិនអាចយកមកអនុវត្តនៅអ.វ.ត.ក បានដែរ។

### *សហកម្មឧក្រិដ្ឋកម្មរួមជាទម្រង់នៃការចូលរួម និងការដឹងមុនបាន*

២៧. ការអនុវត្តសហកម្មឧក្រិដ្ឋកម្មរួមនៅក្នុង អ.វ.ត.ក មិនមែនជាការរំលោភបំពានទៅលើគោលការណ៍ *គោលការណ៍គ្មានច្បាប់គឺគ្មានទោស* ដែលមានចែងក្នុងមាត្រា១៥(១) នៃអនុសញ្ញាស្តី

---

[62] *អយ្យការ v.Karemera,* សំណុំរឿងក្តីលេខ. ICTR-98-44-T, សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង III នៅ ICTR ស្តីពីញត្តិគាំទ្របឋម ដែលជំទាស់នឹងយុត្តាធិការ ទាក់ទងនឹងសហកម្មឧក្រិដ្ឋកម្មរួម, ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៤ វាក្យខណ្ឌ ៣២-៣៨។

ពីសិទ្ធពលរដ្ឋ និងសិទ្ធនយោបាយ ("ICCPR") និងមានចែងផងដែរនៅក្នុងមាត្រា៣៣ នៃច្បាប់បង្កើត អ.វ.ត.ក នោះទេ។ ដូចបានពិភាក្សារួចមកហើយ គិតត្រឹមឆ្នាំ១៩៧៥ សហកម្មឧក្រិដ្ឋកម្មរួម គឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដូចមានរៀបរាប់យ៉ាងច្បាស់នៅក្នុងវគ្គខណ្ឌ៣១-៣៨នៃសេចក្ដីសន្និដ្ឋានតប ដូច្នេះជនដែលត្រូវចោទទាំងអស់នោះអាចបានចូលរួម និងដឹងមុនបានយ៉ាងពេញលេញក្នុងពេលដែលបានបទឧក្រិដ្ឋអស់ទាំងនោះត្រូវបានប្រព្រឹត្ត។

២៨. ដោយការដកស្រង់សំណុំរឿងក្ដីរបស់ *Tadic* ដែលជនត្រូវចោទបានលើកឡើងថា សំណុំរឿងក្ដីទាំង១០ នៃច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យ ដែលអង្គជំនុំជម្រះតុលាការឧទ្ធរណ៍ ICTY យកជាមូលដ្ឋាននោះ ជាសំណុំរឿងក្ដី ដែល"មិនទាន់បានផ្សព្វផ្សាយនៅឡើយទេ" ហើយក្នុងករណីខ្លះទៀត សំណុំរឿងទាំងនោះគឺគ្រាន់តែជាការសង្ខេបខ្លះៗនៃសាលក្រម ដែលមិនបានសរសេរជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ។ សំណើដែលថា តុលាការមិនត្រូវប្រមែប្រមូលសំណុំរឿងក្ដីទាំងនោះមកធ្វើជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ ព្រោះមិនត្រូវចាត់ទុកថាចុងចោទមានការយល់ដឹងពេញលេញពីសំណុំឯកសារ ដែលមិនទាន់បានផ្សព្វផ្សាយទាក់ទងនឹងទ្រឹស្ដីច្បាប់ នោះគឺជាសំណើដែលមិនអាចទទួលយកបានទេ *(គោលការណ៍ច្បាប់ដែលចែងថា ការមិនដឹងច្បាប់មិនអាចធ្វើឱ្យបុគ្គលនោះរួចខ្លួនពីការទទួលខុសត្រូវនោះទេ [ignorantia juris non excusat])*។ ការប្រកាន់យកជំហរបែបនេះមិនត្រឹមត្រូវទេ ជាក់ស្ដែងសំណុំរឿងក្ដី ដែលពាក់ព័ន្ធនឹងច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ ភាគច្រើនត្រូវបានផ្សព្វផ្សាយជាទម្រង់សង្ខេបនៅក្នុងរបាយការណ៍ជាផ្លូវការអង្គការសហប្រជាជាតិស្ដីពីការប្រព្រឹត្តបទឧក្រិដ្ឋសង្គ្រាម ក្នុងឆ្នាំ១៩៤៩ រួចទៅហើយ។ បើពិនិត្យទៅលើអារម្ភកថា នៃរបាយការណ៍ទាំងនោះ "គោលបំណង ជាចម្បង នៃរបាយការណ៍ទាំងនោះ [គឺ] ជួយស្រាយបំភ្លឺច្បាប់ ដូចជាផ្នែកខ្លះនៃច្បាប់អន្តរជាតិ ដែលត្រូវបានគេហៅថាជាច្បាប់សង្គ្រាម"[63]។ សេចក្ដីសម្រេចរបស់អង្គ

---

[63] អារម្ភកថា របាយការណ៍ច្បាប់ទាក់ទងសវនាការស្ដីពីបទឧក្រិដ្ឋសង្គ្រាម, XV UNWCC, ទំព័រ vii (១៩៤៩)។ ក្នុងពេលដែលគណៈកម្មាការការប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាមអង្គការសហប្រជាជាតិ ទទួលស្គាល់ថា នៅពេលដែល "គ្មានសាលក្រមដែលគ្មានសម្អាងហេតុ ក្នុងករណីខ្លះវាមានការលំបាកក្នុងការបញ្ជាក់ឱ្យបានច្បាស់ពីមូលហេតុដែលជម្រុញឱ្យតុលាការផ្ដល់សេចក្ដីសម្រេច" គណៈកម្មាការបានបន្ថែមទៀតថា៖ "ទោះជាយ៉ាងណាក៏ដោយ ការលំបាក

00268550



សវនាការ ដែលមានអាជ្ញាប្រព្រឹត្ត និងត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ ហើយបានទទួលស្គាល់ និងអនុវត្តដោយសាលាក្តីឧក្រិដ្ឋកម្មសង្គ្រាម គឺជាសេចក្តីសម្រេច ដែលគាំទ្រដល់ទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញា នៅក្នុងសេចក្តីសន្និដ្ឋានតបរបស់ខ្លួន ដែលថា បុគ្គលម្នាក់ៗសុទ្ធតែបានដឹងឮគ្រប់គ្រាន់ ក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ថា បទឧក្រិដ្ឋយង់ឃ្នងទៅលើហ្វូងមនុស្ស គឺសុទ្ធតែជាទង្វើដែលនឹងតម្រូវឱ្យពួកគេទទួលខុសត្រូវ ដោយគោរពទៅតាមទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម។ លើសពីនេះទៅទៀត ដូចមជ្ឈមណ្ឌលសិទ្ធមនុស្ស និងពហុនីតិ (Center for Human Rights and Legal Pluralism) នៃសាកលវិទ្យាល័យ McGill បានលើកឡើងក្នុងកថាខណ្ឌ១៣ នៃសារណារបស់ខ្លួនថា វិធីសាស្ត្ររបស់តុលាការ *ពិសេស* ផ្សេងៗទៀតបានសន្មតថា លក្ខខណ្ឌតម្រូវឱ្យមានការអាចដឹងមុន និងការអាចចូលរួម នឹងត្រូវបានបំពេញ ប្រសិនបើទង្វើឧក្រិដ្ឋត្រូវគេ កំនត់ថាអាចផ្តន្ទាទោសបានក្រោមច្បាប់អន្តរជាតិ។

*សហកម្មឧក្រិដ្ឋកម្មរួមមានចែងក្នុងមាត្រា២៥នៃច្បាប់ការបង្កើតអ.វ.ត.ក*

២៥. ជនត្រូវចោទបានតវ៉ាថា ដោយទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួមមិនបានចែងនៅក្នុងច្បាប់នៃការបង្កើតអ.វ.ត.ក - ឯកសារមួយដែលបានទទួលការអនុម័តបន្ទាប់ពីលក្ខន្តិកៈ ICC ដែលបានទទួលស្គាល់យ៉ាងច្បាស់ចំពោះទ្រឹស្តីនោះ - បានសេចក្តីថា ឯកសារច្បាប់ជាមូលដ្ឋានរបស់តុលាការនេះ បានបដិសេធសហកម្មឧក្រិដ្ឋកម្មរួមជាទម្រង់នៃការទទួលខុសត្រូវ ដោយជាក់ស្តែងរួចទៅហើយ[64]។ សហព្រះរាជអាជ្ញាស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតបដិសេធការលើកឡើងនេះ*ក្នុងចំណោមការលើកឡើងផ្សេងៗទៀតនោះ* ដោយយោងទៅលើហេតុផលចំនួនបី។

---

នោះគឺ ការខិតខំពុះពារជំនះយ៉ាងខ្លាំងក្លា នៅក្នុង[នៅក្នុងសំណុំរឿងក្តីបែបនោះ] តាមរយៈការត្រួតពិនិត្យដីកាចោទប្រកាន់ សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីទាំងសងខាង និងសាលក្រមឱ្យបានហ្មត់ចត់”

[64] ពាក្យសុំ កថាខណ្ឌ ៦។

00268551



៣០. ទីមួយ ចំពោះមាត្រា២៩ នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក ដែលតម្រូវឱ្យទទួលខុសត្រូវទៅលើការប្រព្រឹត្តបទឧក្រិដ្ឋជាបុគ្គល ចំពោះជនសង្ស័យណាមួយដែល "មានផែនការ ញុះញង់ ដាក់បញ្ជា ជួយនិងជម្រុញក្នុងការរៀបចំផែនការ ឬបានប្រព្រឹត្ត" នូវបទឧក្រិដ្ឋទាំងនោះ នឹងត្រូវទទួលការផ្តន្ទាទោសពីអង្គជំនុំជម្រះនោះ គឺគ្រាន់តែជាការរៀបពាក្យពេជន៍ និងដើម្បីឆ្លុះបញ្ចាំងពីលក្ខណៈដូចគ្នាទៅនឹងបញ្ញត្តិនៃលក្ខន្តិកៈសម្រាប់ ICTY, ICTR និង SCSL តែប៉ុណ្ណោះ។ សាលាក្តីអន្តរជាតិ និងសាលក្តីសកលភាវូបនីយកម្ម បានចាត់ទុកពាក្យ "បានប្រព្រឹត្ត" ដោយរួមបញ្ចូលទាំងការចូលរួម ដើម្បីឱ្យបានសម្រេចគោលបំណង នៃផែនការរួម[65]។ ទោះបីជាអង្គជំនុំជម្រះនេះមិនជាប់កាតព្វកិច្ចត្រូវគោរពទៅតាមការប្រតិបត្តិ របស់សាលាក្តីមុនៗក៏ដោយ ការងាកចេញពីការបកស្រាយបទប្បញ្ញត្តិលក្ខន្តិកៈ ដែលមានពាក្យពេជន៍ ដូចគ្នា នឹងនាំឱ្យមានភាពមិនស៊ីសង្វាក់គ្នា និងភាពមិនអាចព្យាករបាន ក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងធ្វើឱ្យអ.វ.ត.ក ស្ថិតនៅដាច់ដោយឡែកពីស្ថាប័នអន្តរជាតិ ដែលទទួលបានការគោរពទាំងនេះ។

៣១. ទីពីរ ក្នុងពេលដែលច្បាប់ស្តីពីការបង្កើតអ.វ.ត.កត្រូវបានអនុម័តក្នុងឆ្នាំ២០០១ អ្នកដែលធ្វើសេចក្តីព្រាងច្បាប់នេះ បានយល់ដឹងរួចទៅហើយអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការឧទ្ធរណ៍នៅ ICTY ក្នុងសំណុំរឿង *Tadic*។ ជាក់ស្តែង ពួកគេបានដឹងថា ការទទួលខុសត្រូវចំពោះសហកម្មឧក្រិដ្ឋកម្មរួមមានចែងនៅក្នុងមាត្រា៧(១) ក្នុងលក្ខន្តិកៈរបស់ ICTY ស្តីអំពីមូលដ្ឋាន វត្ថុនិស័យ និងគោលបំណងរបស់លក្ខន្តិកៈ ចរិតលក្ខណៈបទឧក្រិដ្ឋអន្តរជាតិ ការពិនិត្យឡើងវិញទៅលើយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីII និងបានសិក្សាប្រៀបធៀប

[65] *សំណុំរឿងក្តី CDF,* លេខ. SCSL-04-14-T, សេចក្តីសម្រេចចំពោះញត្តិគាំទ្រចំពោះការសម្រេចឱ្យរួចទោសអនុលោមតាមវិធាន ៩៨ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៥ កថាខណ្ឌ ១៣០៖ "តាមផ្លូវច្បាប់ ជាទូទៅ អង្គជំនុំជម្រះយល់ឃើញថា មាត្រា៦(១)លក្ខន្តិកៈរបស់តុលាការពិសេស ក្នុងផ្នែកនៃការដាក់ឱ្យនៅក្រៅច្បាប់ មិនបានកំណត់ថាការទទួលខុសត្រូវទៅលើបទឧក្រិដ្ឋមានចំពោះតែជនទាំងឡាយណា ដែលមានផែនការ ញុះញង់ ដាក់បញ្ជា ឬបានប្រព្រឹត្តបទឧក្រិដ្ឋដោយផ្ទាល់ ឬជនដែលជួយនិងជម្រុញក្នុងការរៀបចំ ធ្វើផែនការ ឬការអនុវត្តនោះឡើយ។ ព្រំដែននៃការដាក់ឱ្យនៅក្រៅច្បាប់មានហួសពីការទប់ស្កាត់មិនឱ្យមានបទល្មើស តាមរយៈសហកម្មឧក្រិដ្ឋកម្មរួម ដែលក្នុងផែនការរួម ដើម្បីប្រព្រឹត្តបទឧក្រិដ្ឋ ដែលអាចផ្តន្ទាទោសតាមលក្ខន្តិកៈ"។

ពីច្បាប់របស់បណ្តាប្រទេសមួយចំនួនផងដែរ[66]។ ដូច្នេះ ប្រសិនបើអ្នកដែលធ្វើសេចក្តីព្រាងច្បាប់នេះមិនចង់រួមបញ្ចូលសហកម្មឧក្រិដ្ឋកម្មរួម ដោយជាក់ស្តែង ដូចដែលពាក្យសុំបានលើកឡើងនោះ ពួកគេមិនចាំបាច់រំលឹកឡើងវិញដោយចំពោះ ក្នុងមាត្រា៧(១) នៃលក្ខន្តិកៈ ICTY និងមាត្រា២៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក នោះទេ។ ផ្ទុយទៅវិញ ពួកគេប្រហែលជាតាក់តែងច្បាប់នេះទៅតាមវិធីសាស្ត្រ ដែលអ្នករៀបរៀងសេចក្តីព្រាងលក្ខន្តិកៈក្រុងរ៉ូម នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលបានអនុម័ត ដោយប្រើពាក្យពេជន៍ផ្សេងពីនេះបាត់ទៅហើយ។ លក្ខន្តិកៈក្រុងរ៉ូមបានប្រើពាក្យ សហចារី ជាជាងការប្រើពាក្យសហកម្មឧក្រិដ្ឋកម្មរួម និងកែប្រែទ្រឹស្តីនេះបន្តិចដោយតម្រូវឱ្យមាន "ការដឹងឮ" ចំពោះរាល់ទម្រង់ទាំងបីនៃការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួម[67]។

៣២. សូមលើកយកឧទាហរណ៍ជាក់ស្តែងដែលឆ្លុះបញ្ចាំងពីវិធីសាស្ត្រដែលទើបនឹងរៀបរាប់មុននេះបន្តិចនោះ គឺលក្ខន្តិកៈរបស់ ក្រុមប្រឹក្សាពិសេសរបស់ទីម័រខាងកើត សម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរ

---

[66] សេចក្តីសម្រេចអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿងក្តី Tadic វាក្យខណ្ឌ ១៨៩, ១៩១, ១៩៥-២២៦។

[67] មិនដូចនឹងទម្រង់ទីមួយនៃសហកម្មឧក្រិដ្ឋកម្មរួមដែលអនុវត្តនៅតុលាការអន្តរជាតិនានា ICC មិនតម្រូវឱ្យជនជាប់ចោទចូលរួមក្នុង *បំណងឧក្រិដ្ឋ* ជាមួយនឹងជនដែលនោះទេ ផ្ទុយនឹងទម្រង់ទីបីនៃសហកម្មឧក្រិដ្ឋកម្មរួម បញ្ញត្តិទាក់ទងនឹងសហកម្មឧក្រិដ្ឋកម្មរួមរបស់ ICC តម្រូវឱ្យមានការដឹងឮ ជាជាងការអាចដឹងជាមុនបាន។ សូមមើល *លក្ខន្តិកៈក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ* UN Doc. A/CONF. 183/9 (1998), មាត្រា២៥។ ដោយ ICC បានប្រើវាក្យស័ព្ទ "ការប្រព្រឹត្តរួម" ជាជាងសហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងយុត្តាធិការរបស់ខ្លួនក្នុងការទទួលខុសត្រូវចំពោះមាត្រា២៥ ទើបនៅក្នុងសាលក្រមរបស់ ICC ដែលទើបនឹងសម្រេចទៅលើបញ្ហានេះបង្ហាញថា សហកម្មឧក្រិដ្ឋកម្មរួមត្រូវបានយកមកអនុវត្តដោយគ្រាន់តែប្រើឈ្មោះផ្សេង និងមានទម្រង់ខុសគ្នាបន្តិចប៉ុណ្ណោះ។ សូមមើល *អយ្យការ v. Germain Katanga និង Mathieu Ngudjolo Chi,* សំណុំរឿងក្តីលេខ: ICC-01/04-01/07, ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៨ កថាខណ្ឌ ៥៣៣។ ("អង្គជំនុំជម្រះយល់ឃើញថា ការប្រព្រឹត្តបទឧក្រិដ្ឋរួម តម្រូវឱ្យជនសង្ស័យទាំងពីរ៖ (ក) ត្រូវដឹងជាមុនដូចគ្នាថា ការអនុវត្តផែនការរួម របស់ពួកគេនេះនឹងជម្រុញឱ្យសម្រេចបាននូវគោលបំណងក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ (ខ) បានប្រព្រឹត្តសកម្មភាព ទាំងនោះក្នុងចេតនាជាក់លាក់ដើម្បីសម្រេចនូវគោលបំណងក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ ឬជនសង្ស័យទាំងពីរ បានដឹងមុនរួចទៅហើយថាការសម្រេចបាននូវគោលបំណងនោះ នឹងតម្រូវឱ្យពួកគេប្រឈមនឹងលទ្ធផលដែលពួកគេ ត្រូវទទួលយកលទ្ធផលដែលបណ្តាលមកពីព្រឹត្តិការដែលបានកើតឡើង"។)

(East Timor Special Panels for Serious Crimes) ដែលបានអនុម័តក្នុងឆ្នាំ២០០០ មួយឆ្នាំមុនច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ លក្ខន្តិកៈនេះបានប្រើប្រាស់ពាក្យពេជន៍ក្នុង មាត្រា២៥ ទៅតាមលក្ខន្តិកៈក្រុងរ៉ូម ជាជាងលក្ខន្តិកៈរបស់ ICTY, ICTR, SCSL និង រូបមន្តរបស់ អ.វ.ត.ក នោះទេ[68]។ ដូច្នេះ ជាជាងការផ្តល់នូវចេតនាជាក់ស្តែងក្នុងការបដិសេធ សហកម្មឧក្រិដ្ឋកម្មរួម ការសម្រេចចិត្តរបស់អ្នកធ្វើសេចក្តីព្រាងច្បាប់នោះគឺថា មិនទទួលយក ពាក្យពេជន៍ ដែលមានក្នុងលក្ខន្តិកៈក្រុងរ៉ូមមកប្រើប្រាស់ទេ ឬការមិនរួមបញ្ចូលសហកម្ម ឧក្រិដ្ឋកម្មរួម ដោយជាក់លាក់នេះ ដើម្បីធានាថាមាត្រា២៩ នឹងមិនត្រូវបកស្រាយក្នុងចេតនា ស្របគ្នាទៅនឹងវិធីសាស្ត្រនៃតុលាការ*ពិសេស*នានា ជាក់ស្តែងគឺមានអត្ថន័យផ្ទុយពីគេ៖ អ្នកធ្វើ សេចក្តីព្រាងច្បាប់ទាំងនេះ មានគោលបំណងចង់ឲ្យ អ.វ.ត.ក ប្រតិបត្តិទៅ តាម ការអនុវត្តនៅក្នុងសំណុំរឿងក្តី *Tadic* ជាជាងប្រតិបត្តិទៅតាមរូបមន្តតូចចង្អៀត នៃលក្ខន្តិកៈ ក្រុងរ៉ូម។

៣៣. ជាងនេះទៅទៀត សំណើក្នុងសេចក្តីអង្កេតបន្ថែម ដែលថា ភាពខុសគ្នារវាង "នាំមកវិនិច្ឆ័យទោស" ជាគោលបំណងនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និង "កាត់ទោស" ដែលប្រើនៅក្នុងលក្ខន្តិកៈ របស់ICTY ជាមូលដ្ឋានក្នុងការបកស្រាយមាត្រា២៩ គឺសុទ្ធតែជាសំណើដែលមិនមាន សនិទានកម្ម និងមិនមានឯកសារជាប្រភពយោងទេ[69]។ វាក្យស័ព្ទទាំងពីរនេះមានអត្ថន័យ ស្រដៀងគ្នា៖ គេអាចស្រមើស្រម៉ៃឃើញដោយលំបាក ថាតើ អ.វ.ត.ក អាចនាំយកមេដឹកនាំ ជាន់ខ្ពស់នៃរបបខ្មែរក្រហម និងអ្នកដែល ទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋដែលបាន

---

[68] UN រដ្ឋបាលបណ្តោះអាសន្ននៅទីម័រខាងកើត (Transitional Administration in East Timor), វិធានលេខ: 2000/15 ស្តីពីការបង្កើតអង្គចៅក្រមក្នុងយុត្តាធិការពិសេសដោយឡែកសម្រាប់បទល្មើសឧក្រិដ្ឋធ្ងន់ធ្ងរ (Establishment of Panels with Exclusive Jurisdiction over Serious Criminal Offences) ផ្នែក ១៤.៣(ឃ) UN Doc. UNTAET/REG/2000/15.6, ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០០។ លក្ខន្តិកៈតុលាការពិសេសនៅ Lebannon ក៏អនុម័ត យកវិធីសាស្ត្រស្រដៀងគ្នានេះដែរ។ សូមមើលមាត្រា៣(១)(ខ) Republic ស្តីពីការបង្កើតតុលាការពិសេសនៅ Lebannon ជាឧបសម្ព័ន្ធនឹងក្រុមប្រឹក្សាសន្តិសុខ S.C. Res. 1757, U.N. SCOR, 58th Sess., 5685th mtg., U.N. Doc. S/RES/1757 (ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧)។

[69] សេចក្តីអង្កេតបន្ថែម, កថាខណ្ឌ ១៧។

ប្រព្រឹត្តក្នុងរបបនោះយកមកវិនិច្ឆ័យទោស ដោយគ្មានការកាត់ទោស ឬក៏កាត់ទោស ដោយគ្មានការវិនិច្ឆ័យទោស យ៉ាងដូចម្ដេចបានទៅ។

៣៤. ទីបី សញ្ញាណ ដែលថាមាត្រា២៩ចែងពីសហកម្មឧក្រិដ្ឋកម្មរួមនោះ ត្រូវបានអះអាងនៅក្នុងវត្ថុនិស័យ និងគោលបំណងនៃច្បាប់ស្ដីពីការបង្កើតអ.វ.ត.ក។ មាត្រា១ នៃច្បាប់នេះចែងថា ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោស "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត។ ប្រយោគដែលស្ដែងពីគោលបំណងនេះ បានបញ្ជាក់យ៉ាងច្បាស់ថា អង្គជំនុំជម្រះនឹងផ្ដោតទៅលើបទឧក្រិដ្ឋទាំងជាតិ និងអន្តរជាតិក្នុងទ្រង់ទ្រាយធំនានា។

៣៥. មានការទទួលស្គាល់ជាបន្តបន្ទាប់ បន្ទាប់ពីមានសវនាការនៅ Nuremberg រួចមក ថាវាជាលក្ខណៈសំគាល់ពិសេសដោយឡែកនៃបទឧក្រិដ្ឋ ដែលបានបញ្ជាក់ និងតម្រូវឱ្យមានការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួម ដែលអាចបំពេញលក្ខខណ្ឌ នៃការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួម។ លក្ខណៈពិសេសនេះមានពន្យល់បកស្រាយនៅក្នុងសំណុំរឿងក្ដី *Tadic*:

> ភាគច្រើនបទឧក្រិដ្ឋទាំងនេះមិនមែនកើតឡើងមកពីការប្រព្រឹត្តបទឧក្រិដ្ឋ របស់បុគ្គលម្នាក់ៗនោះទេ ប៉ុន្តែវាជាការរួមគ្នាប្រព្រឹត្តនូវបទឧក្រិដ្ឋរួម៖ ជាញឹកញាប់ បទឧក្រិដ្ឋទាំងនេះប្រព្រឹត្តទៅជាក្រុមប្រតិបត្តិទៅតាមផែនការឧក្រិដ្ឋកម្មរួមមួយ។ ទោះបីជាមានតែសមាជិកក្នុងក្រុមមួយចំនួន ដែលបានប្រព្រឹត្តសកម្មភាពបទឧក្រិដ្ឋដោយផ្ទាល់ក៏ដោយ (ធ្វើឃាត ការសម្លាប់បំផុតពូជ ការបំផ្លាញភូមិ ទីប្រជុំជន និងទីក្រុងយ៉ាងព្រៃផ្សៃ ជាដើម) ក៏ការចូលរួម និងរួមចំណែករបស់សមាជិកដទៃទៀតរបស់ក្រុមនេះ គឺមិនអាចខ្វះបាន ក្នុងការជួយសម្រួលដល់ការប្រព្រឹត្តទៅនៃបទល្មើស ដែលនឹងត្រូវប្រព្រឹត្ត។
> ជាមួយគ្នានេះដែរ ស្ថានទម្ងន់ទោសខាងផ្នែកសីលធម៌ ក្នុងការចូលរួមក្នុងការប្រព្រឹត្តបទឧក្រិដ្ឋបែបនេះវិញ ក៏មិនស្រាលជាង - ឬតាមពិតមិនខុសគ្នា - ពីជនទាំងឡាយដែលបានប្រព្រឹត្តបទឧក្រិដ្ឋដោយផ្ទាល់នោះទេ[70]។

---

[70] សេចក្ដីសម្រេចអង្គជំនុំជម្រះតុលាការកំពូលអំពីសំណុំរឿងក្ដី Tadic កថាខណ្ឌ ១៩១។

ខ្លឹមសារបែបនេះ ត្រូវបានដកស្រង់នៅក្នុងសេចក្តីសម្រេចរបស់ ICTY ជាបន្តបន្ទាប់[71] និងនៅក្នុងសំណុំរឿងក្តី *Karemera* អង្គជំនុំជម្រះសាលាដំបូង ICTR បានបញ្ជាក់យ៉ាងច្បាស់ ពីហេតុផលស្រដៀងគ្នាមួយ ចំពោះទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម៖

> ការដែលឱ្យមានការទទួលខុសត្រូវជាចារីចំពោះតែបុគ្គលណា ដែលបានប្រព្រឹត្តបទល្មើសជាក់ស្តែង គឺជាទង្វើបដិសេធតួនាទីសហចារី របស់បុគ្គលដទៃទៀត ដែលបានចូលរួមក្នុងរបៀបផ្សេងគ្នា ហើយជួយសម្រួលឱ្យមានការកើតឡើងនូវបទល្មើសនោះ។ ផ្ទុយទៅវិញ ការឱ្យបុគ្គលដែលមិនមែនជាចារីផ្ទាល់ទទួលខុសត្រូវត្រឹមតែជាអ្នកជួយនិងជម្រុញ អាចធ្វើឱ្យពួកគេទទួលខុសត្រូវព្រហ្មទណ្ឌស្រាលជាងទោសជាក់ស្តែង[72]។

៣៦. សំណើបានដកស្រង់ការថ្លែងយោបល់តុលាការ និងមតិរិះគន់តែមួយចំនួនប៉ុណ្ណោះចំពោះទ្រឹស្តីសហកម្មឧក្រិដ្ឋកម្ម ក្នុងការផ្តល់ការគាំទ្រដល់សំណុំរឿងក្តីរបស់ជនត្រូវចោទ ដើម្បីការពារកុំឱ្យមានការអនុវត្តសហកម្មឧក្រិដ្ឋកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ[73]។ មន្ត្រីតុលាការដ៏ច្រើនលើសលប់នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ បានពិនិត្យមើលចំណោទបញ្ហា នឹងសម្រេចអនុវត្ត

---

[71] សូមមើល ឧទាហរណ៍ *អយ្យការ v. Kvacka និងជនឯទៀត* សំណុំរឿងក្តីលេខ: IT-98-30/1-A, សេចក្តីសម្រេចអង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌ ៨០ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥។ *អយ្យការ v. Krnojelac* សំណុំរឿងក្តីលេខ: IT-97-25-A, សេចក្តីសម្រេចអង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌ ២៩ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៣។ *អយ្យការ v. Blagojevic និងJokic* សំណុំរឿងក្តីលេខ: IT-02-60-T, សាលក្រមអង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៩៥ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥។

[72] *អយ្យការ v. Edourad Karemera, Mathieu Ngurumpatse, Joseph Nzirorera និង Andre Rwamakuba* សំណុំរឿងក្តីលេខ: ICTR-98-44-T, សេចក្តីសម្រេចស្តីពី បណ្តឹងបឋម របស់មេធាវីការពារក្តី ប្រឆាំងយុត្តាធិការទាក់ទងនឹងសហកម្មឧក្រិដ្ឋកម្មរួម, សាលក្រមអង្គជំនុំជម្រះសាលាដំបូង III កថាខណ្ឌ ៣៦ ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៤។

[73] ជនត្រូវចោទបានដកស្រង់ការថ្លែងយោបល់ផ្នែកខ្លះរបស់ចៅក្រម Liu នៅក្នុងរឿងក្តីរវាង *អយ្យការ v. Oric,* សំណុំរឿងក្តីលេខ: IT-03-68-A, សេចក្តីសម្រេចអង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌ ២៦ ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៨ និងការថ្លែងយោបល់ផ្នែកខ្លះរបស់ចៅក្រម Shahabuddeen នៅក្នុងរឿងក្តីរវាង *អយ្យកា v. Hadzihasanovic & Kubura* សំណុំរឿងក្តីលេខ: IT-01-47-AR47, សេចក្តីសម្រេចស្តីពី ឧទ្ធរណ៍បន្ទាន់បង្គំជំទាស់នឹងយុត្តាធិការ ទាក់ទងនឹងការទទួលខុសត្រូវរបស់មេកើយ កថាខណ្ឌ ២១ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៣។

ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម។ ស្រដៀងគ្នានេះដែរ ក្រុមអ្នកស្រាវជ្រាវ បានផ្តល់ការគាំទ្រជាទូទៅចំពោះទ្រឹស្តីនេះ ដោយពិចារណាទៅលើតម្រូវការដោយឡែកក្នុងការនាំយកជនទាំងឡាយដែលទទួលខុសត្រូវចំពោះបទឧក្រិដ្ឋយង់ឃ្នង ក្នុងទ្រង់ទ្រាយធំនេះមកវិនិច្ឆ័យទោស។ អ្នកស្រាវជ្រាវមួយរូបបានអះអាងថា សហកម្មឧក្រិដ្ឋកម្មរួមអាច "ពង្រឹងមុខងារប្រាប់ការពិតនៃសវនាការទាក់ទងនឹងច្បាប់ព្រហ្មទណ្ឌអន្តរជាតិបាន តាមរយៈការពណ៌នាដែលមានលក្ខណៈច្បាស់លាស់ជាងទ្រឹស្តីនៃការទទួលខុសត្រូវផ្សេងៗទៀត ក្នុងការស្វែងយល់ ថាតើបទឧក្រិដ្ឋត្រូវបានចាប់ផ្តើម ត្រូវបានរៀបចំ និងអនុវត្តដោយរបៀបណា នៅក្នុងបរិបទឧក្រិដ្ឋកម្មជាប្រព័ន្ធនោះ"[74]។ អ្នកស្រាវជ្រាវមួយរូបទៀតបាននិយាយថា "វាគឺជាដំណើរធម្មតានៃបទឧក្រិដ្ឋអន្តរជាតិដែលត្រូវតែជាបទឧក្រិដ្ឋ ក្នុងទ្រង់ទ្រាយធំប្រព្រឹត្តឡើងដោយពហុចារី និងជាញឹកញាប់ភស្តុតាងនៃការចូលរួមរបស់ជនជាប់ចោទមិនសូវសំបូរទេ"[75]។ ស្រដៀងគ្នានេះដែរ សាស្ត្រាចារ្យ Antonio Cassese ជាអគ្គនិពន្ធនាយក នៃ *ទស្សនាវដ្តីយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ* បានបញ្ចេញមតិថា៖

> ឧក្រិដ្ឋកម្មអន្តរជាតិ ដូចជា ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ ការធ្វើទារុណកម្ម និងភេរវកម្មសុទ្ធតែមានលក្ខណៈសំគាល់រួម៖ បទឧក្រិដ្ឋទាំងនេះបង្ហាញឲ្យឃើញពីឧក្រិដ្ឋកម្មជារួម ដែលមានការចូលរួមអនុវត្តពីបុគ្គលជាច្រើនប្រភេទ ដូចជា យោធា កងជីវពល ឬមន្ត្រីដែលចូលរួមជាឯកច្ឆន្ទ ឬករណីភាគច្រើន ជាការអនុវត្តគោលនយោបាយអ្វីមួយ។ នៅពេលដែលមានការប្រព្រឹត្តបទឧក្រិដ្ឋបែបនេះ វាមានការលំបាកក្នុងការកំនត់ឲ្យបានចំពោះការចូលរួមចំណែករបស់បុគ្គលម្នាក់ៗ នៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម ឬបទឧក្រិដ្ឋរួមនេះ [...] សញ្ញាណនៃសហកម្មឧក្រិដ្ឋកម្មរួម ជាអ្នកកំណត់នូវទម្រង់ការទទួលខុសត្រូវលើបទឧក្រិដ្ឋ ដែលលេចឡើងជាក់លាក់ដោយសមរម្យសម្រាប់បិតបាំងការទទួលខុសត្រូវលើបទឧក្រិដ្ឋ របស់អ្នកចូលរួម ដទៃៗទៀតនៅក្នុងផែនការរួមមួយនោះ[76]។

---

74 Katrina Gustafson, លក្ខខណ្ឌនៃ "កិច្ចព្រមព្រៀងបន្ទាន់" ចំពោះការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួម, *មតិរិះគន់របស់ Brdjanin,* 5J, INT"L CRIM. JUS. 134 (2007) ទំព័រ ១៣៩។

75 CIARA DAMGAAD, ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលចំពោះ ឧក្រិដ្ឋកម្មអន្តរជាតិសំខាន់ៗ 235 (២០០៨)

76 ANTONIO CASSESE, ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ (បោះពុម្ពផ្សាយលើកទីពីរ ២០០៨) ទំព័រ ១៨៩-១៩១។

សូម្បីតែ Mark Osiel ដែលជាអ្នកសរសេររិះគន់ចំពោះសហកម្មឧក្រិដ្ឋកម្មរួមនោះ ក៏ទទួលស្គាល់ផងដែរថា៖

> មួយវិញទៀតនោះ ការចូលរួមសហកម្ម មានលក្ខណៈស៊ីសង្វាក់គ្នានឹងវិសាលភាពផ្សេងៗគ្នា នៃអំពើសាហាវយង់ឃ្នងច្រើនជាង ដែលឥទ្ធិពលព្យាបាទរាលដាលក្នុងប្រព័ន្ធរប៉ាត់រប៉ាយ និងមិនផ្លូវការ [...] ភាពទន់ភ្លន់នៃអង្គការ ត្រូវតែស៊ីសង្វាក់គ្នាជាមួយនឹងភាពទន់ភ្លន់នៃទ្រឹស្តី ដើម្បីធ្វើឱ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ដន្ទាទោសបញ្ចាំងទង្វើខុសឆ្គងរបស់ចុងចោទ[77]។

៣៧. ហេតុដូច្នេះ សំណើរបស់សេចក្តីអង្កេតបន្ថែម ដែលថា ការបកស្រាយ "មាត្រា២៩ ដែលត្រូវរួមបញ្ចូលទម្រង់ការទទួលខុសត្រូវមួយ មានលក្ខណៈខុសប្លែកពីប្រព័ន្ធច្បាប់ចែង គឺជាការផ្ទុយគ្នាទាំងស្រុង" ទៅនឹងវត្ថុបំណង និងគោលបំណងរបស់អង្គជំនុំជម្រះនោះ ជាការភ័ន្តច្រឡំ[78]។ ជាក់ស្តែង អ្នកធ្វើសេចក្តីព្រាងច្បាប់មានបំណងបញ្ចូលទម្រង់ទាំងបីនៃការទទួលខុសត្រូវរបស់សហកម្មឧក្រិដ្ឋកម្មរួមទៅក្នុងមាត្រា២៩ បើមិនដូច្នោះទេ ពួកគេនឹងពន្យល់បកស្រាយបញ្ជាក់ពីការមិនរួមបញ្ចូលនេះជាក់ជាមិនខានឡើយ។

### *ច្បាប់ទំនៀមទម្លាប់អន្តរជាតិអាចយកមកអនុវត្តបានទៅ អ.វ.ត.ក*

៣៨. អង្គជំនុំជម្រះយល់ឃើញថា អ.វ.ត.ក គឺជាសាលាក្តីគោរពទៅតាមបទដ្ឋានអន្តរជាតិពិសេសមួយដែលទទួលយកវិធាននិងបទដ្ឋានអន្តរជាតិនានាមកអនុវត្ត[79]។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ក៏បានចែងយ៉ាងច្បាស់ផងដែរថា ការស្វែងរកការណែនាំជាជំនួយផ្សេងៗ ត្រូវតែធ្វើតាមនីតិវិធី ដែលរៀបចំឡើងក្នុងកម្រិតអន្តរជាតិ[80]។

---

77 Mark Osiel, *The Banality of Good: Aligning Incentives Against Mass Atrocity, 105 COLUMBIA LAW REVIEW,* 1751, 1771 (2005)។

78 សេចក្តីអង្កេតបន្ថែម កថាខណ្ឌ ១៩។

79 សេចក្តីសម្រេចរបស់ចៅក្រម ន័យ ថុល កថាខណ្ឌ ៣០។

80 សូមមើល ជាឧទាហរណ៍ មាត្រា៣៣ថ្មី។

00268558

D427/I/OCIJ (PTC) 37/8

៣៩. លើសពីនេះទៀត មាត្រា១៥(២) កតិកាសញ្ញាស្តីពីសិទ្ធពលរដ្ឋនិងសិទ្ធនយោបាយ ICCPR ក៏បានឆ្លុះបញ្ចាំងផងដែរ ពីគោលការណ៍មូលដ្ឋានដែលផ្តល់សិទ្ធឱ្យតុលាការជាតិអាចជំនុំជម្រះបទឧក្រិដ្ឋអន្តរជាតិ បានតាមរយៈការប្រើប្រាស់ទម្រង់នានា នៃការទទួលខុសត្រូវ ដែលមានការទទួលស្គាល់ក្នុងកម្រិតអន្តរជាតិ ថាតើបទឧក្រិដ្ឋបែបនោះ ឬទម្រង់ទទួលខុសត្រូវបែបនោះ បានទទួលស្គាល់ដោយច្បាប់ជាតិ នៅក្នុងរយៈពេលដែលបទឧក្រិដ្ឋទាំងនោះបានប្រព្រឹត្តឡើងដែរ ឬយ៉ាងណា[81]។ វានឹងមិនស៊ីសង្វាក់គ្នាតាមផ្លូវច្បាប់ទេ ប្រសិនបើអង្គជំនុំជម្រះនេះត្រូវជំនុំជម្រះក្តី ដោយគ្មានលទ្ធភាពអនុវត្តទម្រង់នៃការទទួលខុសត្រូវយ៉ាងសាមញ្ញ ដែលភ្ជាប់មកជាមួយនឹងបទឧក្រិដ្ឋនៅក្នុងច្បាប់អន្តរជាតិផងនោះ។ សេចក្តីអង្កេតបន្ថែមអះអាងដោយភ័ន្តច្រឡំ ថា "[អ.វ.ត.ក] អាចអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិបាន លុះត្រាតែទទួលបានការអនុញ្ញាត ឬជាកាតព្វកិច្ចតម្រូវដោយច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា"[82]។

## គ. ទម្រង់ទីIII នៃសហឧក្រិដ្ឋកម្មរួម មិនបានដាក់ឱ្យមានទម្រង់នៃពិរុទ្ធដោយការជាប់ពាក់ព័ន្ធ ហើយក៏មិនបានធ្វើឱ្យមានភាពនៃការប៉ះពាល់កេរ្តិ៍ឈ្មោះ សមាជិករាជរដ្ឋាភិបាល និងសង្គមកម្ពុជាដែរ

---

81 ICCPR មាត្រា១៥(២)៖ "គ្មានបញ្ញត្តិណាមួយក្នុងមាត្រានេះ ប្រឆាំងនឹងការជំនុំជម្រះក្តី ឬការផ្តន្ទាទោសដល់ជនណាម្នាក់ចំពោះអំពើ ឬការខកខានណាមួយ ដែលជននោះបានប្រព្រឹត្ត ក្នុងខណៈពេលដែលអំពើ ឬការខកខាននោះ ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមគោលការណ៍ទូទៅនៃច្បាប់ ដែលទទួលស្គាល់ដោយសហគមន៍នៃប្រជាជាតិ"។ *អយ្យការ v. Milan Milutinovic, Nikola Sainovic & Dragoljub Odjanic,* សេចក្តីសម្រេចអង្គជំនុំជម្រះតុលាការកំពូល ស្តីពី Motion Challenging Jurisdiction - សហឧក្រិដ្ឋកម្មរួម សំណុំរឿងក្តីលេខ: IT-99-37-AR72 ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ ៤១-៤២ [*បន្ទាប់ពីនេះទៅហៅថា* សេចក្តីសម្រេចពីសហឧក្រិដ្ឋកម្ម រួម Ojdanic] (ដោយកត់សំគាល់ថា ការអនុវត្តសហឧក្រិដ្ឋកម្មរួម ទៅលើបទឧក្រិដ្ឋនៅ Bosnia មានលក្ខណៈ ស្របច្បាប់ ទោះបីជាអតីតយូហ្គោស្លាវីមិនទទួលស្គាល់ពីទម្រង់នៃការទទួលខុសត្រូវក៏ដោយ)។ សហព្រះរាជអាជ្ញា បានកត់សំគាល់ថា ច្បាប់កម្ពុជាបានទទួលស្គាល់ទម្រង់ទាំងបីនៃការទទួលខុសត្រូវជាក្រុម ដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងសហឧក្រិដ្ឋកម្មរួមក្នុងឆ្នាំ ១៩៧៦-១៩៧៩៖ (១) ការចូលរួមប្រព្រឹត្ត (២) ការសមគំនិត និង(៣) ការចូលរួមផ្តើមគំនិត។ ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ សៀវភៅ II មាត្រា ៨២ (ការចូលរួមប្រព្រឹត្ត និងការសមគំនិត) និងមាត្រា ១៤៥ (ការចូលរួមផ្តើមគំនិត)។

82 សេចក្តីអង្កេតបន្ថែម កថាខណ្ឌ ៦៣។

៤០. ក្រៅពីការធ្វើឱ្យមានការភ្ញាក់ផ្អើលដល់មតិសាធារណជន និងការលេងល្បែងនយោបាយក្នុងដំណើរការស្វែងរកយុត្តិធម៌ ការបកស្រាយរបស់ជនត្រូវចោទ ចំពោះទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម ហើយនិងសក្តានុពល ដែលខ្លួនបានលើកឡើងថានឹងធ្វើឱ្យ "មានការទទួលខុសត្រូវដ៏ធំធេងមួយ" គឺជាការបកស្រាយបំផ្លើសវិសាលភាពនៃទ្រឹស្តី និងផលលំបាក ដែលបណ្តាលមកពីការអនុវត្តទម្រង់នៃការទទួលខុសត្រូវបទឧក្រិដ្ឋមួយនេះ។

៤១. មិនដូចជាអ្វីដែលជនត្រូវចោទបានអះអាងនោះទេ សហកម្មឧក្រិដ្ឋកម្មរួម មិនបានលំអៀងជ្រុលមកខាងអយ្យការទេ ឬក៏ធ្វើឱ្យប៉ះពាល់ដោយអយុត្តិធម៌ចំពោះជំហររបស់ចុងចោទដែរ។ ជាក់ស្តែង នៅមានហេតុផលយ៉ាងហោចណាស់បួនទៀត ដែលបដិសេធការលើកឡើងថាបទដ្ឋាននៃភាពអាចដឹងទុកជាមុន ដែលជាមូលដ្ឋាននៃទម្រង់ទី III របស់សហកម្មឧក្រិដ្ឋកម្មរួមនោះ ដាក់ឱ្យមានទម្រង់នៃពិរុទ្ធ ដោយការជាប់ពាក់ព័ន្ធ ឬការទទួលខុសត្រូវដ៏តឹងរ៉ឹងចំពោះភាពជាសមាជិកនៅក្នុងស្ថាប័នព្រហ្មទណ្ឌ។

៤២. ទីមួយ ការទទួលខុសត្រូវនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម មានលក្ខណៈខុសប្លែកពីបទឧក្រិដ្ឋនៃភាពជាសមាជិកនៅក្នុងស្ថាប័នព្រហ្មទណ្ឌ។ បទឧក្រិដ្ឋនៃភាពជាសមាជិក ត្រូវបានចាត់ជាបទល្មើសដាច់ដោយឡែកនៅ Nuremberg និងនៅក្នុងសវនាការជាបន្តបន្ទាប់ដែលជំនុំជម្រះក្រោមច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ ដែលនៅក្នុងការជំនុំជម្រះទាំងនោះ បានកំណត់ថា ការស្គាល់និងការស្ម័គ្រចិត្តធ្វើជាសមាជិកភាពនៅក្នុងស្ថាប័នមួយ ដែលត្រូវគេចាត់ទុកថាជាស្ថាប័នព្រហ្មទណ្ឌនោះ មានលក្ខណៈគ្រប់គ្រាន់ចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលហើយ។ នៅ Nuremberg បទល្មើសនៃការលាក់កំបាំងសមាជិកភាព នៅក្នុងស្ថាប័នព្រហ្មទណ្ឌមួយនោះ ត្រូវបានអនុម័តដើម្បីជួយសម្រួលដល់ការចោទប្រកាន់ដែលធ្វើឡើងចំពោះជនល្មើសកម្រិតស្រាលនៅពេលក្រោយៗទៀត[83]។ ផ្ទុយទៅវិញ ការទទួលខុសត្រូវព្រហ្មទណ្ឌ អនុលោមទៅតាមទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម មិនមែនជាការទទួលខុសត្រូវដែលកើតមានចំពោះតែសមាជិកភាពប៉ុណ្ណោះទេ ប៉ុន្តែ "វាជាទម្រង់នៃការទទួលខុសត្រូវពាក់

[83] របាយការណ៍ច្បាប់ស្តីពីសវនាការទាក់ទងនឹងឧក្រិដ្ឋកម្មសង្គ្រាម XV ទំព័រ ៩៨-៩៩។

ព័ន្ធនឹងការចូលរួមក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ ដែលជាផ្នែកមួយនៃសហកម្មឧក្រិដ្ឋកម្មរួម ដែលជាបញ្ហាមួយផ្សេងទៀត”[84]។

៤៣. ទីពីរ ការអះអាងស្តីពីការទទួលខុសត្រូវនៃសហកម្មឧក្រិដ្ឋកម្មរួមនោះ មានចែងនៅក្នុងឯកសារគោលនយោបាយសាធារណៈ ជាច្រើន។ មានន័យថា វាជាតម្រូវការដែលត្រូវ ការពារសង្គមឱ្យផុតពីបុគ្គលដែល (១) រួមដៃគ្នាប្រព្រឹត្តសហកម្មឧក្រិដ្ឋកម្មរួម (២) ទោះជាមិនបានចូលរួមដោយចេតនាដើម្បីប្រព្រឹត្តឧក្រិដ្ឋរួម ជាមួយនឹងជនទាំងឡាយដែលមានបំណងនឹងប្រព្រឹត្តបទឧក្រិដ្ឋធ្ងន់ធ្ងរបែបនោះ ដែលមិនស្ថិតនៅក្នុងផែនការសហកម្មរួមក៏ដោយ ក៏យ៉ាងហោចណាស់អ្នកទាំងនោះក៏បានដឹងជាមុនដែរថា បទឧក្រិដ្ឋទាំងនោះអាចនឹងត្រូវគេប្រព្រឹត្ត ហើយ (៣) ដែលខ្លួនអាចប្រឆាំងរារាំង ឬហាមឃាត់មិនឱ្យមានការប្រព្រឹត្តរបស់ពួកគេធ្វើទៅបាន[85]។ ដូចតុលាការជាន់ខ្ពស់នៃប្រទេសអង់គ្លេស និង វេល (Wales) បានកត់សំគាល់ថា “បទពិសោធន៍បានបង្ហាញរួចមកហើយថា សហកម្មឧក្រិដ្ឋកម្មរួម បានត្រៀមលក្ខណៈយ៉ាងល្អរួចទៅហើយក្នុងការជម្រុញឱ្យកើតមាននូវការប្រព្រឹត្តិបទល្មើសក្នុងទ្រង់ទ្រាយធំនានា”[86]។ ដូច្នេះ ការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួម គឺមានយុត្តិកម្ម ទាំងដោយការគម្រាមកំហែងយ៉ាងពិសេសដែលបង្កឡើងដោយបទឧក្រិដ្ឋដែលបានរៀបចំ និងទាំងបញ្ហាប្រឈមយ៉ាងពិសេសក្នុងការចោទប្រកាន់ចារីទាំងនោះផងដែរ។

៤៤. ទីបី ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មចៃដន្យ យោងទៅលើការយល់ពីហេតុការណ៍មុន និងទៅលើហានិយភ័យ គឺជាទម្រង់នៃការទទួលខុសត្រូវ ដែលអាស្រ័យលើ និងមានភាពជួនគ្នាចំពោះផែនការឧក្រិដ្ឋកម្មរួមមួយ។ “បទឧក្រិដ្ឋចៃដន្យ” អាចបកស្រាយបានថា ជាបទឧក្រិដ្ឋកើតចេញ និងដោយយោងទៅលើផែនការរួមដែលមានអត្ថិភាពរួចជាស្រេច ក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋជារួម ឬសកម្មភាពបទឧក្រិដ្ឋជាបឋមនៃសហកម្មឧក្រិដ្ឋកម្មរួម។ ឬនិយាយម្យ៉ាង

---

[84] សេចក្តីសម្រេចស្តីពីសហកម្មឧក្រិដ្ឋកម្មរួម Ojdanic កថាខណ្ឌ ២៥។

[85] Antonio Cassese, *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* (បោះពុម្ពផ្សាយលើកទីពីរ ២០០៨) ទំព័រ ២០២។

[86] *Regina v. Powell និង Regina v. English* (ការយល់ឃើញរបស់ Lord Steyn) ដកស្រង់ដោយ Antonio Cassese *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* (បោះពុម្ពផ្សាយលើកទីពីរ ២០០៨) ទំព័រ ២០៣។

ទៀតថា វាមានទំនាក់ទំនងហេតុនិងផលរវាងឧក្រិដ្ឋដែលបានគ្រោងទុក និងឧក្រិដ្ឋកម្មផ្សេងទៀត។ ទោះបីជាជនដែលបន្ទាប់បន្សំមិនមានចេតនា ក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋផ្សេងទៀតជាមួយនឹងជនដែលក៏ដោយ ក៏ពិរុទ្ធភាពរបស់ជននេះស្ថិតនៅត្រង់អង្គហេតុដែលថា ជននេះអាចរំពឹងទុកពីការប្រព្រឹត្តិបទឧក្រិដ្ឋនោះ ប៉ុន្តែនៅតែមានចេតនាទទួលយកហានិភ័យដែលអាចនឹងកើតមាន។ ជននោះគួរណាស់តែបានរារាំងបទឧក្រិដ្ឋបន្ថែមនោះ ឬផ្តាច់ខ្លួនចេញពីការប្រព្រឹត្តអំពើឧក្រិដ្ឋនោះតែម្តង ដូច្នេះការខកខានមិនធ្វើបែបនេះ បង្ហាញថា ជននេះក៏ត្រូវតែទទួលខុសត្រូវផងដែរចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋនោះ[87]។ ករណីនេះមានការខុសប្លែកពីស្ថានភាពផ្សេងៗដែលបទឧក្រិដ្ឋបានកើតចេញពីផែនការមួយ ដែលមានលក្ខណៈស្របច្បាប់ តាំងពីពេលចាប់ផ្តើម។ ក្នុងស្ថានភាពមួយចំនួន ដូចជា ពេលអង្គភាពយោធាប្រតិបត្តិសកម្មភាពយោធាស្របច្បាប់មួយ ហើយមានសមាជិកណាម្នាក់ប្រព្រឹត្តសកម្មភាពដាច់ដោយឡែក ដែលជាសកម្មភាពខុសច្បាប់ នោះការទទួលខុសត្រូវចំពោះពិរុទ្ធភាពនៃសកម្មភាពនោះ នឹងទទួលខុសត្រូវដោយចារីប្រព្រឹត្តតែប៉ុណ្ណោះ។

៤៥. ទីបួន អង្គជំនុំជម្រះអាចធ្វើការពិចារណាទៅលើកម្រិតខុសៗគ្នាក្នុងការផ្តន្ទាទោសទៅលើពិរុទ្ធភាពរបស់អ្នកដែលចូលរួមនៅក្នុងការប្រព្រឹត្តិសហកម្មឧក្រិដ្ឋកម្មរួមនេះ នៅអង្គសវនាការវិនិច្ឆ័យទោស[88]។

៤៦. ជនត្រូវចោទបានចោទសួរពីភាពមិនច្បាស់លាស់ដែលបានលើកឡើងនៅក្នុងបទដ្ឋាន "ភាពអាចដឹងទុកជាមុន" នៃសហកម្មឧក្រិដ្ឋកម្មរួមក្នុងទម្រង់ទីIII។ ទោះបីជាយ៉ាងណាក៏ដោយ ក៏តុលាការក្រមជាតិ និងអន្តរជាតិធ្លាប់បានអនុវត្តរួចមកហើយកាលពីពេលមុន នូវបទដ្ឋានបែបនេះក្នុងចរិតម៉ឺងម៉ាត់ និងប្រកបដោយយុត្តិធម៌នៅក្នុងបរិបទជាច្រើនក្នុងច្បាប់ព្រហ្មទណ្ឌ។ ការពិតវត្ថុបំណងនៃបទដ្ឋាន "ភាពអាចដឹងទុកជាមុន" នេះ ក៏អាចអនុវត្តផងដែរនៅក្នុងបរិបទសម្រាប់បញ្ជាក់ពី "ការជ្រោមជ្រែងឱ្យប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ" ឬ "ការទទួលខុសត្រូវ

---

[87] Antonio Cassese, *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* (បោះពុម្ពផ្សាយលើកទីពីរ ២០០៨) ទំព័រ ២០២។

[88] ដូចឯកសារយោងពីខាងដើម ទំព័រ ២០២-២០៥។

ក្នុងការបញ្ជា"ជាដើម។ ដូចក្នុងទម្រង់ទីIII នៃសហកម្មឧក្រិដ្ឋកម្មរួម ក្នុងការបញ្ជាក់ពីការជ្រោមជ្រែងឲ្យប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ គឺយោងទៅលើការសាកល្បងដើម្បីបញ្ជាក់ពីគោលបំណងមួយសិន ថាតើចុងចោទបានដឹងទេថាបទឧក្រិដ្ឋ "អាចនឹងត្រូវគេប្រព្រឹត្ត" ដែរឬទេនោះ[89]។ ក៏ដូចគ្នានឹងទម្រង់ទីIII នៃសហកម្មឧក្រិដ្ឋកម្មរួមដដែលនេះដែរ ការទទួលខុសត្រូវក្នុងការបញ្ជា ត្រូវប្រើការសាកល្បង "ភាពអាចដឹងទុកជាមុន" មួយ ដើម្បីកំណត់ថាតើ (១) សកម្មភាព ឬការខកខាន ដែលនាំមកនូវការទទួលខុសត្រូវព្រហ្មទណ្ឌនោះ ត្រូវបានប្រព្រឹត្តដោយបុគ្គលដែលមិនមែនជាជនជាប់ចោទ (២) មានទំនាក់ទំនងរវាងថ្នាក់លើ និងថ្នាក់ក្រោមបង្គាប់រវាងជនជាប់ចោទ និងចារីដែលជាជនដៃដល់ (៣) ជនជាប់ចោទដែលជាថ្នាក់លើ បានដឹង ឬក៏មានហេតុផលដែលអាចដឹងបានថា ជនក្រោមបង្គាប់អាចនឹងប្រព្រឹត្តបទឧក្រិដ្ឋបែបនោះ ឬក៏បានប្រព្រឹត្តបទឧក្រិដ្ឋនោះរួចទៅហើយ (៤) ជនជាប់ចោទក្នុងឋានៈជាថ្នាក់លើ ខកខានមិនបានចាត់វិធានការណ៍ឲ្យបានសមរម្យ និងមិនបានរាំងបទឧក្រិដ្ឋ ឬដាក់ទោសចារីក្នុងពេលនោះ[90]។ តាមការពិត បទដ្ឋានការទទួលខុសត្រូវក្នុងការបញ្ជា "មានហេតុផលអាចដឹង" គឺជាការសាកល្បងពីវត្ថុបំណងមួយដែលបានតម្រូវឲ្យមាន *បំណងឧក្រិដ្ឋ* ទាបជាងអ្វីដែលទម្រង់ទីIII នៃសហកម្មឧក្រិដ្ឋកម្មរួមតម្រូវឲ្យមាន។

៤៧. បញ្ហាដែលនៅសល់ហើយមិនទាន់ចុះសម្រុងគ្នានោះ មិនមែនស្ថិតនៅត្រង់ថាការទទួលខុសត្រូវរបស់សហកម្មឧក្រិដ្ឋកម្មរួមដែលមានចែងក្នុងច្បាប់អន្តរជាតិនោះទេ គឺស្ថិតនៅលក្ខខណ្ឌបែបណាដែលការទទួលខុសត្រូវនោះត្រូវយកមកអនុវត្ត។ សហព្រះរាជអាជ្ញាបានលើកឡើងថា យុត្តាធិការរបស់តុលាការពិសេសដទៃទៀត បានពណ៌នាជាប្រព័ន្ធ និងយ៉ាងច្បាស់លាស់ ហើយចំពោះទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មក្នុងទម្រង់III ដែលការពណ៌នានេះគឺជាការពណ៌នាយ៉ាងជាក់ច្បាស់រួចទៅហើយ។ ជាក់ស្តែង ហេតុផលនេះអាចសម្រេចទៅបានដោយការតម្រូវបន្ថែមទៅលើការចូលរួមជាក់ស្តែងរបស់ចុងចោទ ក្នុងការសម្រេចបាននូវផែនការឧក្រិដ្ឋកម្មរួម

---

89 *អយ្យការ v. Furundzjia,* សាលក្រមអង្គជំនុំជម្រះសាលាដំបូង សំណុំរឿងក្តីលេខ: IT-95-17/1-T, ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៨ កថាខណ្ឌ ២៤៦។

90 *អយ្យការ v. Oric,* សាលក្រម សំណុំរឿងក្តីលេខ: IT-03-68-T, ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៦ កថាខណ្ឌ ២៩៤។

គាត់ក៏ត្រូវ: (ក) យ៉ាងហោចណាស់ ចូលរួមក្នុងចេតនាឧក្រិដ្ឋ (ខ) បានដឹងពីលទ្ធភាពដែលបទឧក្រិដ្ឋអាចកើតមានប្រសិនបើប្រតិបត្តិផែនការសកម្មភាពឧក្រិដ្ឋកម្ម និងមានចេតនាទទួលយកហានិយភ័យ ដែលអាចកើតមាន។ ដូច្នេះ បទឧក្រិដ្ឋមិនមែនត្រឹមតែអាចផលវិបាកដែលអាចដឹងទុកជាមុន ឬដោយតាមធម្មតា នៃការតម្រូវឱ្យចូលរួមក្នុងផែនការ (ដែលទាក់ទងនឹងការសាកល្បងពីវត្ថុបំណង ចង់ដឹងពី*ចេតនាធ្វើមិនដឹងមិនឮ* ប៉ុណ្ណោះទេ ជនជាប់ចោទក៏ត្រូវមានចេតនាក្នុងការទទួលយកហានិយភ័យផងដែរ ក្រៅពីបានដឹងពីផលវិបាកដែលអាចដឹងជាមុនបានហើយនោះ[91]។

៤៨. លើសពីនេះទៅទៀត អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ ICTY បានសម្រេចដោយគ្មានការស្ទាក់ស្ទើរព្យាយាមការពារទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម មិនឱ្យរាលដាល និងមិនក្លាយជាអរូបី។ ឧទាហរណ៍ ក្នុងរឿងក្តី *Krnojelac* អង្គជំនុំជម្រះបានសម្រេចថា ការប្រើសហកម្មឧក្រិដ្ឋកម្មរួមជាទម្រង់នៃការទទួលខុសត្រូវមួយនោះ "តម្រូវឱ្យកំនត់ឱ្យបានជាក់លាក់នូវនិយមន័យរបស់គោលបំណងរួម" ហើយចារីដែលជាជនដែលបានប្រព្រឹត្តបទឧក្រិដ្ឋដោយផ្ទាល់នោះ "ត្រូវតែកំនត់ឱ្យបានច្បាស់ តាមលទ្ធភាពដែលអាចធ្វើបាន"[92]។

៤៩. យោងការពិចារណាបន្ថែមលើផ្នែកច្បាប់ ពាក្យសុំបានលើកឡើងនូវសមាជិកសំខាន់ៗនៃរដ្ឋាភិបាលកម្ពុជាជាច្រើន - ដែលជនត្រូវចោទបានលើកឡើង - អាចនឹង "ត្រូវប៉ះពាល់កេរ្តិ៍ឈ្មោះ" ក្នុងនាមជាសមាជិករបស់សហកម្មឧក្រិដ្ឋកម្មរួម ប្រសិនបើទម្រង់នៃការទទួលខុសត្រូវនេះត្រូវយកមកអនុវត្តនៅ អ.វ.ត.ក។ ការបារម្ភដែលមាននោះ មិនមានអ្វីជាសំអាងទេ។ ដូចមានបញ្ជាក់ច្បាស់នៅក្នុងការពិភាក្សាពីខាងលើរួចមកហើយ ប្រសិនបើទម្រង់ការទទួល

---

[91] សូមមើល *អយ្យការ v. Babic,* សាលក្រមផ្តន្ទាទោសរបស់អង្គជំនុំជម្រះតុលាការកំពូល ICTY ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៥ កថាខណ្ឌ ២៧។ (ជនជាប់ចោទត្រូវទទួលខុសត្រូវក្នុងទម្រង់ទីបីនៃសហកម្មឧក្រិដ្ឋកម្មរួម "ដរាបណាបទឧក្រិដ្ឋបន្ទាប់បន្សំ អាចដឹងទុកជាមុន ហើយជននោះមានចេតនាទទួលយកហានិយភ័យដែលពួកគេបានប្រព្រឹត្តនោះតាមច្បាប់ ជននោះមាន "ចេតនា"ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះហើយ")។

[92] *អយ្យការ v. Krnojelac,* សេចក្តីសម្រេចអង្គជំនុំជម្រះតុលាការកំពូល សំណុំរឿងក្តីលេខ: IT-97-25-A, ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៣ កថាខណ្ឌ ១១៦។

ខុសត្រូវទាំងបី នៃសហកម្មឧក្រិដ្ឋកម្មរួមត្រូវយកមកអនុវត្តទាំងអស់ដោយត្រឹមត្រូវនោះ គឺធ្វើឡើងមានចំពោះតែការទទួលខុសត្រូវជាបុគ្គល ជនដែលបានចូលរួម (ខុសពីការដែលគ្រាន់តែបានដឹង) ក្នុងគោលបំណងរួមជាមួយជនឯទៀតៗនោះ *ជាក់ស្តែង* បានចូលរួមជម្រុញឱ្យគោលបំណងឧក្រិដ្ឋកម្មនោះ ដោយមានចេតនាផ្ទាល់ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋដែលកើតមាននៅក្នុងផែនការនោះ[93]។ នៅក្នុងបញ្ហានេះ ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួមមិនអាចអនុវត្តបានចំពោះជនត្រូវចោទ ឬក៏ចំពោះជនត្រូវចោទបួនរូបផ្សេងទៀតទេ ដោយសារតែពួកគេបានគាំទ្ររបបនោះ។ ជាងនេះទៅទៀត ពួកគេត្រូវទទួលការចោទប្រកាន់ពីបទយល់ព្រម និងចូលរួមនៅក្នុងផែនការរួមដែលរួមមានស្ថានភាពជាក់ស្តែងផ្សេងៗគ្នាចំនួនម្ភៃប្រាំ នៃមនុស្សឃាត ការធ្វើទារុណកម្ម ការជម្លៀសទាំងបង្ខំ ការបង្ខាំងមនុស្សដោយខុសច្បាប់ ការបង្ខំឱ្យធ្វើការ និងការធ្វើទុក្ខបុកម្នេញជាតិសាសន៍ នយោបាយ និងសាសនា ដែលបានប្រព្រឹត្តក្នុងទ្រង់ទ្រាយមួយយ៉ាងធំ។

## ៤. សេចក្តីសន្និដ្ឋាន និងសំណើ

៥០. សហព្រះរាជអាជ្ញាស្នើថា ពាក្យសុំ និងសេចក្តីអង្កេតបន្ថែមមានគោលបំណងយកដំណើរការតុលាការធ្វើនយោបាយ តាមរយៈការព្យាយាមបង្កើតការភ័យខ្លាចដែលគ្មានអ្វីជាសំអាង ចំពោះការចោទប្រកាន់ឈ្មោះសមាជិកក្នុងសង្គមកម្ពុជា។ ជាក់ស្តែង វត្ថុបំណងនៃពាក្យសុំគឺមិនគាំទ្រឱ្យសហចៅក្រមស៊ើបអង្កេតអនុវត្តទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលមានការទទួលស្គាល់ជាអន្តរជាតិនៅ អ.វ.ត.កទេ។ ជាមួយគ្នានេះដែរ សហចៅក្រមស៊ើបអង្កេតត្រូវតែទទួលស្គាល់ផងដែរថា ការបដិសេធមិនអនុវត្តការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួមនេះ អាចបញ្ជាក់យ៉ាងច្បាស់ថា អ.វ.ត.ក មិនអាចជំនុំជម្រះក្តីប្រកបដោយប្រសិទ្ធភាពចំពោះបទឧក្រិដ្ឋយង់ឃ្នងក្នុងទ្រង់ទ្រាយធំរបស់ខ្មែរក្រហមបានឡើយ។ នេះជាការឃ្លាតចាកពីយុត្តិសាស្ត្រ

---

[93] *អយ្យការ v. Brdjanin, សេចក្តីសម្រេច*អង្គជំនុំជម្រះតុលាការកំពូល សំណុំរឿងក្តីលេខ: IT-99-36, ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ ៤៣០។

របស់តុលាការឧក្រិដ្ឋកម្មសង្គ្រាម ដោយ Nuremberg នឹងត្រូវគេយល់ឃើញទាំង ថ្នាក់ជាតិ និងអន្តរជាតិថាអនុញ្ញាតឲ្យជនត្រូវចោទរួចផុតពីការទទួលខុសត្រូវ ដោយយោងទៅលើបញ្ហាបច្ចេកទេសផ្នែកច្បាប់ដោយឡែករបស់ អ.វ.ត.ក។ ទង្វើបែបនេះមានសក្តានុពលបង្កឲ្យមានអស្ថេរភាពចំពោះកិច្ចដំណើរការនីតិវិធី ដែលប្រជាជនកម្ពុជា និងសហគមន៍ អន្តរជាតិបានទន្ទឹងរង់ចាំអស់រយៈពេលយូរមកហើយ។ ដូច្នេះយោងទៅលើមូលហេតុអស់ទាំងនេះ ពាក្យសុំនេះត្រូវតែច្រានចោល។

៥១. ប្រសិនបើពាក្យសុំត្រូវបានពិចារណាថាអាចទទួលយកបាន នោះសហព្រះរាជអាជ្ញាស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតច្រានចោលពាក្យសុំនេះ ដោយយោងការបដិសេធពីដំបូង ឬ បដិសេធពាក្យសុំនេះដោយយោងលើអង្គសេចក្តី ដែលបង្ហាញថា ទម្រង់ទាំងបីនៃការទទួលខុសត្រូវរបស់សហកម្មឧក្រិដ្ឋកម្មរួម អាចអនុវត្តបាននៅចំពោះមុខអង្គជំនុំជម្រះនេះ៕

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨
**សហព្រះរាជអាជ្ញា**

| | |
|---|---|
| **យ៉េត ចរិយា** | Robert PETIT |
| សហព្រះរាជអាជ្ញារង | សហព្រះរាជអាជ្ញា |